# មាតិកា

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៩-១០-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១០០៤/០០១ ស្តីពីការបង្កើតព្រះរាជលញ្ជករដែលមាន រូបលក្ខណៈភ្ជាប់ជាមួយនេះសំរាប់ប្រថាប់លើព្រះរាជក្រម ឬ ព្រះរាជក្រឹត្យ ដែលមានព្រះហស្តលេខារបស់ព្រះមហាក្សត្រ ឬមានហត្ថលេខារបស់ប្រមុខរដ្ឋស្តីទីតាមព្រះរាជ សារប្រគល់សិទ្ធិពីព្រះមហាក្សត្រ ០១

០២-១១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០០៣ ស្តីពី តែងតាំង អ្នកអង្គ **ស៊ីសុវត្ថិ វឌ្ឍរីឱម៉ង់** នូវឋានៈជា **អ្នកឧកញ៉ា** និងជា **ឯកឧត្តម** ០២

០៤-១១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០០៤ ស្តីពីការ ប្រោសព្រះរាជទាន ចំពោះឯកឧត្តម **ខៀវ កាំដា** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សរឫទ្ធិ** ០៣

០៤-១១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០០៥ ស្តីពីការ តែងតាំងព្រះអង្គម្ចាស់ក្សត្រីយ៍ **ស៊ីសុវត្ថិ សុផាណា** ជាលេខាផ្ទាល់ ព្រះមហាក្សត្រ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ០៤

០៤-១១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០០៦ ស្តីពីការតែងតាំងលោកជំទាវ **អ៊ឹ ចិន្តា** ជាឧបការី ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ មានឋានៈស្មើអនុរដ្ឋលេខាធិការ ០៥

03-12-2004 -KRET NS/KRT/1204/046 NOMMONS Monsieur Khou Leang Hak , Officier de l'ordre Royal du Cambodge , en témoignage de Notre estime . ០៦

03-12-2004 -KRET NS/KRT/1204/047 NOMMONS Maître Michel Buisson , Commandeur de l'Ordre Royal du Sahamétrei , en témoignage de Notre haute considération . ០៧

១៣-១២-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៥៥ ស្តីពីការ កែតំរូវថ្ងៃកំណើតរបស់លោកស្រី **មីជីកូ តូនីតាន់ឌីហ្សូណូ** (MICHIKO Tony Tandijono) ដែលសរសេរខុស ក្នុងកឋាខណ្ឌ (ក) ក្នុងមាត្រា ១ នៃព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរលេខ នស/រកត/ ០២០៣/០៦២ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ០៨

១៧-១២-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៧២ ស្តីពីការ តែងតាំងឯកឧត្តម **ជា ត្រី** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ជា **ឧកញ៉ា** ០៩

| | | |
|---|---|---|
| ១៧-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៧៩ ស្ដីពីការ តែងតាំងឯកឧត្តមឧត្តមសេនីយ៍ត្រី **ឈឿន ចាន់ថន** ជាជំនួយការផ្ទាល់សម្ដេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈ ស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន | ១០ |
| ២៧-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៨២ ស្ដីពីការ ដកហូតឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ពីលោក **ខូច សម្បត្តិ** អត្តលេខ ០០៧៣ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ | ១១ |
| ២៧-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៨៣ស្ដីពីការតម្លើង ឋានន្តរស័ក្តិជូនដល់នាយនគរ បាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០២រូប | ១២ |
| ២៧-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៨៤ ស្ដីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយឯក **ម៉ែន ទិបុល** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ | ១៣ |
| ២៧-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៨៥ ស្ដីពីការ តែងតាំងឯកឧត្តមចំនួន ០២ រូប ជាទីប្រឹក្សាក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ១៤ |
| ២៧-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៨៦ ស្ដីពីការតែងតាំងឯកឧត្តម **ពេជ្រ នុំក្រូទិល** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ **រដ្ឋមន្ត្រី** | ១៥ |
| ២៩-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៨៧ ត្រូវបានបន្ថយរយៈពេលទទួលរងទោសឱ្យទណ្ឌិតដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក | ១៦ |
| ២៩-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៨៨ ស្ដីពីការតម្លើងឋានន្តរសក្តិជាកិច្ចបច្ឆា មរណៈ | ២២ |
| ២៩-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៨៩ ស្ដីពីការតែងតាំងឯកឧត្តម **រ័ត្ន ធិរៈ** ជាអគ្គលេខាធិការរងនៃក្រុមប្រឹក្សាស្ថារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទមានឋានៈស្មើ **អនុរដ្ឋលេខាធិការ** | ២៤ |
| ២៩-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៩០ ស្ដីពីការតែងតាំងឯកឧត្តម **ឈាក សុខា** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ **រដ្ឋលេខាធិការ** | ២៥ |
| ២៩-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៩១ ស្ដីពីការតែងតាំងលោកជំទាវ **ទី សាមីន** ជាទីប្រឹក្សារបស់ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** | ២៦ |

០៤-០១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០០២ ស្តីពីការលុបឈ្មោះឯកឧត្តម **ឈារ សុខ** អតីតរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលទទួលមរណៈភាពដោយរោគាពាធ ចេញពីក្របខ័ណ្ឌគ្រប់គ្រងរដ្ឋបាល ២៧

០៨-០១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០០៣ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្ម ដល់លោក **ទិន មីងទី** (WEN MING TY) សញ្ជាតិដើមចិន កើតនៅឃុំស្រុកជិនជូ ក្រុងតៃប៉ិ កោះតៃវ៉ាន់ ប្រទេសចិន ២៨

## II-ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ

២១-១២-២០០៤ -សេចក្តីសំរេចរួមលេខ ០១ ព.រ.ក ស្តីពីប្រៀវត្សរ៍មូលដ្ឋាន និងប្រាក់បំណាច់ផ្សេងៗ របស់មន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ ២៩

## III-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

០៤-០១-២០០៥ -អនុក្រឹត្យលេខ ០១ អនក្រ.តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ៣៩

០៤-០១-២០០៥ -អនុក្រឹត្យលេខ ០២ អនក្រ.តត ស្តីពីការ ជូនមេដាយសហមេត្រី ៤០

០៤-០១-២០០៥ -អនុក្រឹត្យលេខ ០៣ អនក្រ.តត ស្តីពី ការសំរួល និងប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ ៤១

០៤-០១-២០០៥ -អនុក្រឹត្យលេខ ០៤ អនក្រ.តត ស្តីពីការសំរួល និងតែងតាំងមុខតំណែងជូមន្ត្រីរាជការ ៤៣

០៤-០១-២០០៥ -អនុក្រឹត្យលេខ ០៥ អនក្រ.តត ស្តីពីការសំរួល និងតែងតាំងមុខតំណែងជូមន្ត្រីរាជការ ៤៥

០៤-០១-២០០៥ -អនុក្រឹត្យលេខ ០៦ អនក្រ.តត ស្តីពីការសំរួល និងតែងតាំងមុខតំណែងជូមន្ត្រីរាជការ ៤៧

០៤-០១-២០០៥ -អនុក្រឹត្យលេខ ០៧ អនក្រ.តត ស្តីពី ការសំរួល និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៤៩

០៤-០១-២០០៥ -អនុក្រឹត្យលេខ ០៨ អនក្រ.តត ស្តីពី ការសំរួល និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥១

០៤-០១-២០០៥ -អនុក្រឹត្យលេខ ០៩ អនក្រ.តត ស្តីពី ការសំរួល និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៣

០៤-០១-២០០៥ -អនុក្រឹត្យលេខ ១០ អនក្រ.តត ស្តីពី ការសំរួល និងតែងតាំងមន្ត្រីរាជការ ៥៥

០៤-០១-២០០៥ -អនុក្រឹត្យលេខ ១១ អនក្រ.តត ស្តីពីការ តែងតាំងឋានន្តរស័ក្តិនាយនគរបាលជាតិ ៥៧

០៤-០១-២០០៥ -អនុក្រឹត្យលេខ ១២ អនក្រ.តត ស្តីពីការ ជូនមេដាយការងារ ៥៨

០៤-០១-២០០៥ -អនុក្រឹត្យលេខ ១៣ អនក្រ.តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ៧១

០៤-០១-២០០៥ -អនុក្រឹត្យលេខ ១៤ អនក្រ.តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ៧៤

០៤-០១-២០០៥ -អនុក្រឹត្យលេខ ១៥ អនក្រ.តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ៨០

០៤-០១-២០០៥ -អនុក្រឹត្យលេខ ១៦ អនក្រ.តត ស្តីពីការ ជូនមេដាយសហមេត្រី ៨១

០៤-០១-២០០៥ -អនុក្រឹត្យលេខ ១៧ អនក្រ.តត ស្តីពីការ តែងតាំងមន្ត្រីរាជការ ៨២

## ២-សេចក្តីសំរេច

០៥-០១-២០០៥ -សេចក្តីសំរេចលេខ ០១ សសរ ស្តីពី ការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៨៣

# IV-ការងារបណ្តាក្រសួង

## ១-ធនាគារជាតិ នៃ កម្ពុជា

២៩-១២-២០០៤ -ប្រកាសលេខ ធ ៧.០៤.២០៤ ប្រក ស្តីពី ការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ៨៤

29-12-2004 -Prakas Number B.7.04.204 Pro Kor On Annual Audif of Financial Statements of Banks And Financial Institutions ៨៦

២៩-១២-២០០៤ -ប្រកាសលេខ ធ ៧.០៤.២០៥ ប្រក ស្តីពី សោហ៊ុយអាជ្ញាប័ណ្ណ របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១២០

29-12-2004 -Prakas Number B.7.04.205 Pro Kor On License Fees for Banks and Financial Institutions ១២២

២៩-១២-២០០៤ -ប្រកាសលេខ ធ ៧.០៤.២០៦ ប្រក ស្តីពី វិសោធនកម្មលើប្រកាស ស្តីពី អនុបាតសាធនភាព ១២៤

29-12-2004 Prakas Number B.7.04.206 Pro Kor On Amendment of Prakas RELATING TO THE BANKS' SOLVENCY RATIO ១២៦

២៩-១២-២០០៤ -ប្រកាសលេខ ធ ៧.០៤.២០៧ ប្រក ស្តីពី វិសោធនកម្មលើប្រកាស ស្តីពីសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១២៨

29-12-2004 -Prakas Number B.7.04.207 Pro Kor On Amendment of Prakas RELATING TO LIQUIDITY FOR BANKS FINANCIAL INSTITUTIONS ១៣០

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៣១-១២-២០០៤ -ប្រកាសលេខ ៦៣១ សហវ.ប្រក ស្តីពីការកែសំរួលប្លង់គណនេយ្យទូទៅ នៃ គណនេយ្យរដ្ឋ ១៣២

៣១-១២-២០០៤ -ប្រកាសលេខ ៦៣២ សហវ.ប្រក ស្តីពីការកែសំរួលប្លង់គណនេយ្យទូទៅ នៃ គណនេយ្យថវិកា ខេត្ត-ក្រុង ១៣៥

# ព្រះរាជក្រឹត្យ

នស/រកត/១០០៤/០០៦

## យើង

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សារាជសម្បត្តិ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៤
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/១៦៥ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៤ ស្តីអំពីការតែងតាំងឯកឧត្តម គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង ជាសម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ
- បានទ្រង់យល់សេចក្តីត្រូវការចំពោះមុខ

## ត្រាស់បង្គាប់

**មាត្រា ១ :** បង្កើតព្រះរាជលញ្ជករ ដែលមានរូបលក្ខណៈភ្ជាប់ជាមួយនេះ សំរាប់ប្រថាប់លើព្រះរាជក្រម ឬ ព្រះរាជក្រឹត្យ ដែលមានព្រះហស្តលេខារបស់ព្រះមហាក្សត្រ ឬ មានហត្ថលេខារបស់ប្រមុខរដ្ឋស្តីទី តាមព្រះរាជសារប្រគល់សិទ្ធិពីព្រះមហាក្សត្រ ។

**មាត្រា ២ :** សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីព្រះបរមរាជវាំង ត្រូវទទួលភារៈចាត់ការអនុវត្ត អោយបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៤០៣ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០១ និង ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥៣ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០១ ត្រូវចាត់ទុកជាមោឃៈ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**
**នរោត្តម សីហមុនី**

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៤*

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខ: ០០៦/០៤រ.ចច
រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែវិច្ឆិកាឆ្នាំ២០០៤
រូបភាពព្រះរាជលញ្ជករ ៖ ចម្លាក់អណ្តែត សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
**ហត្ថលេខា និងត្រា**
គង់ សំអុល

រៀបរៀងដោយ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
សណ្ឌី គាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ

សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

## តែងតាំង

**អ្នកអង្គ ស៊ីសុវត្ថិ រដ្ឋារីឌីម៉ង់**
(SISOWATH ROTHARY DIMANG)

ឲ្យឋានៈជា

**ព្រះអង្គម្ចាស់ និងជា ឯកឧត្តម**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៤១១.០០៣

**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង ភ្នំពេញ ថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០០៤*

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខ:០០២/០៤ វរ.ចប
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ វិច្ឆិកា ឆ្នាំ២០០៤
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
ហត្ថលេខា និងត្រា
គង់ សំអុល

លេខ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ខៀវ ក៉ាដា

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ស.០៤១១.០០៤

**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០០៤*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ:០០៣/០៤រ.ចច
រាជធានីភ្នំពេញ ,ថ្ងៃទី០៧ ខែវិច្ឆិកាឆ្នាំ២០០៤
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
ហត្ថលេខា និងត្រា
គង់ សំអុល

លេខ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/១០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

ព្រះអង្គម្ចាស់ក្សត្រិយ៍ ស៊ីសុវត្ថិ សុផាណា

ជា

លេខាធិការផ្ទាល់ ព្រះមហាក្សត្រ
មានឋានៈស្មើ អនុរដ្ឋលេខាធិការ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.០៤១១.០០៥
**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខ:០០៤/០៤ រវ.ចច
រាជធានីភ្នំពេញ .ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៤
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
**ហត្ថលេខា និងត្រា**
គង់ សំអុល

លេខ:៣៤០ច.ប
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ.ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ស៊ុយ សែម

ណារ៉ា គាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតក្ខត្តិយា ខេមរជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោកជំទាវ អ៊ុំ ចិន្តា

ជា

ឧបការី ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ
មានឋានៈស្មើ អនុរដ្ឋលេខាធិការ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ាល.០៤១១.០០៦

**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខ:០០៥/០៤ រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ វិច្ឆិកា ឆ្នាំ២០០៤
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧត្តម
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
ហត្ថលេខា និងត្រា
គង់ សំអុល

លេខ [illegible] ចុ.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណាវី តាន់

# KRET

NS / KRT / 1204 / 046

*Nous*

*Preah Karuna Preah Bat Samdech*
*Preah Boromneath Norodom Sihamoni,*
*Roi du Cambodge*

NOMMONS

*Monsieur* ***Khou Leang Hak,***
*Officier de l'Ordre Royal du Cambodge,*
*en témoignage de Notre estime.*

៣រល.០៤១២.០៤៦
**បានប្រថាប់ព្រះរាជលញ្ឆករហើយ**
*Fait au Palais Royal à Phnom Penh, le 03 Décembre 2004*

Norodom Sihamony

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខ:០០៦/០៤ រ.ចច
រាជធានីភ្នំពេញ ,ថ្ងៃទី ០៩ខែ [illegible] ឆ្នាំ២០០៤
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
**ហត្ថលេខា និងត្រា**
គង់ សំអុល

លេខ: [illegible] ម.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
[illegible]

# KRET

NS / KRT / 1204 / 047

*Nous*

*Preah Karuna Preah Bat Samdech*
*Preah Boromneath Norodom Sihamoni,*
*Roi du Cambodge*

NOMMONS

*Maître* ***Michel Buisson,***
*Commandeur de l'Ordre Royal du Sahamétrei,*
*en témoignage de Notre haute considération.*

នស.រកត.០៤១២.០៤៧
**បានប្រថាប់ព្រះរាជលញ្ឆករហើយ**
*Fait au Palais Royal à Phnom Penh, le 03 Décembre 2004*

Norodom Sihamoni

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខ:០០៧/០៤ រ.ចច
រាជធានីភ្នំពេញ ,ថ្ងៃទី០៨ ខែ ធ្នូ ឆ្នាំ២០០៤
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
**ហត្ថលេខា និងត្រា**
**គង់ សំអុល**

លេខ:៣៤៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ.ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ណារ៉ុង តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៥៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៣/០៦២ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** កែតំរូវថ្ងៃកំណើតរបស់លោកស្រី **មីជីកូ តូនីតាន់ឌីហ្សូណូ** ( MICHIKO Tony Tandijono) ដែលសរសេរខុសក្នុងកឋាខណ្ឌ (ក) ក្នុងមាត្រា ១ នៃព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរលេខ នស/រកត/០២០៣/០៦២ ចុះ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដូចខាងក្រោមនេះ ÷

- លោកស្រី **មីជីកូ តូនីតាន់ឌីហ្សូណូ** កើតថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៥៥

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ ...៣០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ១២ ឆ្នាំ២០០[illegible]
អគ្គលេខាធិការរាជរដ្ឋាភិបាល
[signature]
[illegible] គាន់

តាល.០៤១២.០៥៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤

នស/រកត/១២០៤/០៧២

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

## តែងតាំង

ឯកឧត្តម **ជា គ្រី** ជាទីប្រឹក្សា សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា

ជា

**ឧកញ៉ា**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៤១២.០៧២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤*

លេខ:៣៧៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាង តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៧៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តមឧត្តមសេនីយ៍ត្រី **ឈឿន ចាន់ថន** ជាជំនួយការផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវ ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣.ល.០៤១២.០៧៩

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០០៤

លេខ: ៣៣៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សរាម៉ី តាន់**

នស/រកត/១២០៤/០៨២

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដកហូតឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ពីលោក **ខុច សម្បត្តិ** អត្តលេខ ០០៧៣ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** រាល់ការកំណត់ទាំងឡាយណាដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៤១៤.០៥២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ ២០០៤

លេខ ៣៣៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៨៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៩០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តម្លើងឋានន្តរស័ក្តិជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

**ក- ថ្នាក់ឧត្តមសេនីយ៍ទោ :**

- លោកឧត្តមសេនីយ៍ត្រី ហឿ យុទ្ធ អត្តលេខ ០០២១ ។

**ខ- ថ្នាក់ឧត្តមសេនីយ៍ត្រី :**

- លោកវរសេនីយ៍ឯក យន់ ផៃយ៉ា អត្តលេខ ០០៨០ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បានឃើញ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណារ៉ិ ‑ តាន់

៣រល.០៤១២.០៨៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ ២០០៤

នស/រកត/១២០៤/០៨៤

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យ ប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាទូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **ប៉ែន ចិបូល** អត្តលេខ ០៣៧៦ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៣៣៧ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

៣៧ល.០៤១២.០៩៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៤

ណារិទ្ធិ គាន់

# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៨៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តមចំនួន ០២ រូប ជាទីប្រឹក្សាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **វ៉ន្ត ប៊ុនឡា** ជាទីប្រឹក្សាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

២- ឯកឧត្តម **ខ្វាន់ សាខន** ជាទីប្រឹក្សាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៤*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ពាល.០៤១៤.០៨៥*

លេខ:៣៣៦ ច.ល
**ជូនម្សិចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ស៊ាន់ តាន់

៦/e

# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៨៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **ពៅ ឋុជ នុំក្រមិល** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*តាល.០៤១៧.០៨៦*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៤*

លេខ: ៣៣៧ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ណារី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៨៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានបន្ថយរយៈពេលទទួលរងទោសចំនួន ១២ខែ ឱ្យទណ្ឌិតចំនួន ៣នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ៖

១. ទណ្ឌិតឈ្មោះ នាង សារ៉ែន ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៣-៥-៩៦ ពីបទសម្លាប់មនុស្សដោយចេតនា ប៉ុនប៉ងសម្លាប់មនុស្ស កាន់កាប់អាវុធខុសច្បាប់ និងបង្ករបួសស្នាមដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៦៤ ចុះថ្ងៃទី ២២-៨-៩៧ របស់សាលាឧទ្ធរណ៍ ។

២. ទណ្ឌិតឈ្មោះ នួច ផាន ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-៩-៩៤ ពីបទធ្វើមនុស្សឃាតដោយគិតទុកជាមុន ហើយត្រូវតុលាការ សំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី ២៥-៤-៩៥ របស់តុលាការខេត្តព្រៃវែង ។

៣_ទណ្ឌិតឈ្មោះ **ណុច ញ៉ិល** ហៅ ពន្លក ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣១-១២-៩២ពីបទប្លន់ទ្រព្យសម្បត្តិប្រជាជន និងសម្លាប់មនុស្ស និងកាន់កាប់អាវុធខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៣ ចុះថ្ងៃទី ២៥-៨-៩៣ របស់តុលាការខេត្តព្រៃវែង ។

**មាត្រា ២** : ត្រូវបានបន្ថយរយៈពេលទទួលរងទោសចំនួន ៩ខែ ឱ្យទណ្ឌិតចំនួន ៤នាក់ ដែលបានខិតខំ កែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ៖

១_ ទណ្ឌិតឈ្មោះ **សុខ ណារ៉ត** ភេទស្រី អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៦-៤-២០០១ ពីបទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២"ត" ចុះថ្ងៃទី ២៤-០១-២០០២ របស់តុលាការខេត្តតាកែវ ។

២_ទណ្ឌិតឈ្មោះ **គីម ហុក** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-៤-៩៧ ពីបទសមគំនិតធ្វើអំពើរំលោភ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៦២ ចុះថ្ងៃទី ១៧-៧-៩៧ របស់សាលាឧទ្ធរណ៍ ។

៣_ទណ្ឌិតឈ្មោះ **នួន សុវណ្ណារ៉ុង** ភេទប្រុស អាយុ ២៩ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៤-១១-៩៨ ពីបទភេរវកម្ម ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥"ខ" ចុះថ្ងៃទី ៣១-៨-៩៩ របស់តុលាការក្រុងភ្នំពេញ ។

៤_ទណ្ឌិតឈ្មោះ **គង់ ប្រុង** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-១០-៩៥ ពីបទបាញ់សម្លាប់មនុស្ស ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៩"ត" ចុះថ្ងៃទី ២៤-៩-៩៥ របស់តុលាការក្រុងភ្នំពេញ ។

**មាត្រា ៣** : ត្រូវបានបន្ថយរយៈពេលទទួលរងទោសចំនួន ៦ខែ ឱ្យទណ្ឌិតចំនួន ១៩ នាក់ ដែលបានខិតខំ កែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១_ទណ្ឌិតឈ្មោះ **ពៅ ទីត** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៥-២០០១ ពីបទប្លន់ប្រដាប់អាវុធ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១១"ខ" ចុះថ្ងៃទី ២៦-៣-២០០៣ របស់តុលាការខេត្តតាកែវ ។

២_ទណ្ឌិតឈ្មោះ **ញួង ផេង** ភេទប្រុស អាយុ ៥២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៩-៨-២០០១ ពីបទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ "ត" ចុះថ្ងៃទី ២២-៣-២០០២ របស់តុលាការខេត្តតាកែវ ។

៣_ទណ្ឌិតឈ្មោះ **ហេង រដ្ឋា** ភេទប្រុស អាយុ ៣០ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-០១-២០០២ ពីបទប្លន់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៨"ខ" ចុះថ្ងៃទី ១៦-៧-២០០២ របស់តុលាការខេត្តតាកែវ ។

៤_ទណ្ឌិតឈ្មោះ **ឈិន ចំប៉ែល** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-០១-២០០២ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨០ ចុះថ្ងៃទី ១៧-៩-២០០២ របស់តុលាការខេត្តក្រចេះ ។

៥_ទណ្ឌិតឈ្មោះ **លន់ រតនៈ** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-៣-២០០០ ពីបទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលដីកាលេខ ០៤"ពឞ" ចុះថ្ងៃទី ២២-០១-២០០៣ របស់សាលាឧទ្ធរណ៍ ។

៦_ទណ្ឌិតឈ្មោះ **យន់ គង់** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-១២-៩៨ ពីបទអំពើភេរវកម្ម ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលដីកា លេខ ១៨ "ច" ចុះថ្ងៃទី ០៥-៣-២០០៤ របស់សាលាឧទ្ធរណ៍ ។

៧_ទណ្ឌិតឈ្មោះ **ស្រាក់ ចណ្ណា** ហៅ ជ្រឹម ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣-១២-២០០០ ពីបទប្លន់ទ្រព្យសម្បត្តិពលរដ្ឋ ជួញដូរ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៨៤"ញ" ចុះថ្ងៃទី ២៥-១២-២០០១ របស់តុលាការក្រុងភ្នំពេញ និងលេខ ៣៤ ចុះថ្ងៃទី ១៩-៦-២០០១ របស់តុលាការខេត្តកំពត ។

៨_ទណ្ឌិតឈ្មោះ **សោម ផល** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៤-៣-២០០០ ពីបទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលដីកាលេខ ៦៩ ចុះថ្ងៃទី ២៨-១១-២០០១ របស់តុលាការកំពូល ។

៩_ទណ្ឌិតឈ្មោះ **ហេង ឡាលីន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៣-៩-២០០១ ពីបទចាប់មនុស្សជំរិតយកប្រាក់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១"ជ" ចុះថ្ងៃទី ១៣-៣-២០០២ របស់តុលាការក្រុងភ្នំពេញ ។

១០_ទណ្ឌិតឈ្មោះ **ម៉ក់ ម៉េត** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-១១-២០០១ ពីបទប្លន់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៨"ច" ចុះថ្ងៃទី ០៨-១១-២០០២ របស់តុលាការក្រុងភ្នំពេញ ។



4/7

**១១**_ ទណ្ឌិតឈ្មោះ **សេន ប្រាន** ភេទប្រុស អាយុ ១៨ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៥-២០០២ ពីបទប្លន់និង ប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោស ដាក់ពន្ធនាគារ កំណត់៦ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ " យ " ចុះថ្ងៃទី ០៨-០១ ២០០៣ របស់តុលាការក្រុង ភ្នំពេញ ។

**១២**_ ទណ្ឌិតឈ្មោះ **ម៉ែន សំអឿន** ភេទប្រុស អាយុ ៥៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៨-៧-២០០០ ពីបទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ១១-០១-២០០១ របស់តុលាការខេត្តព្រៃវែង ។

**១៣**_ទណ្ឌិតឈ្មោះ **អន ចេង** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៦-២០០១ ពីបទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១៥ ចុះថ្ងៃទី ២០-១២-២០០១ របស់តុលាការខេត្តព្រៃវែង ។

**១៤**_ ទណ្ឌិតឈ្មោះ **ហឿន ហុន** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៦-២០០២ ពីបទប្លន់មានបក្សពួកមានអាវុធ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨៤ ចុះថ្ងៃទី ២៩-១១-២០០២ របស់តុលាការខេត្តព្រៃវែង ។

**១៥**_ ទណ្ឌិតឈ្មោះ **ពេស ទុំ** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៩-២០០៣ ពីបទឆបោក ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៣ ចុះថ្ងៃទី ០៧-៤-២០០៤ របស់តុលាការក្រុងព្រះសីហនុ ។

**១៦**_ ទណ្ឌិតឈ្មោះ **ជាតិ ពេជ្រ** ភេទប្រុស អាយុ ២០ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៦-៩-២០០២ ពីបទប្លន់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រម លេខ ០៥ ចុះថ្ងៃទី ១៨-០១-២០០១ របស់តុលាការក្រុងព្រះសីហនុ ។

**១៧**_ ទណ្ឌិតឈ្មោះ **នាង ឡឿន** ហៅ ណារី ទាប ភេទស្រី អាយុ ៥២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-១១-២០០១ ពីបទឆបោក ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ២៨-០១-២០០២ និងលេខ ៣៨ ចុះថ្ងៃទី ៣០-៥-២០០២ របស់តុលាការក្រុងព្រះសីហនុ ។

**១៨**_ ទណ្ឌិតឈ្មោះ **ចំន្ទ សុភ័ណ្ឌ** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-១២-២០០២ ពីបទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៤៩ ចុះថ្ងៃទី ០២-៤-២០០៣ របស់តុលាការក្រុងព្រះសីហនុ ។



5/7-

១៩- ទណ្ឌិតឈ្មោះ **នុត សំណាង** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-១២-២០០២ ពីបទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៤៩ ចុះថ្ងៃទី ០២-៤-២០០៣ របស់តុលាការក្រុងព្រះសីហនុ ។

**មាត្រា ៤** : ត្រូវបានលើកលែងទោសឱ្យទណ្ឌិតចំនួន ៦នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេល រងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ៖

១- ទណ្ឌិតឈ្មោះ **រ័ត្ន សំ** ភេទប្រុស អាយុ ២០ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-៧-២០០៣ ពីបទចោរកម្ម ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២៨ ខែ តាមអំណាចសាលក្រមលេខ ៦"ខ" ចុះថ្ងៃទី ២៦-០១-២០០៤ និងលេខ ០៧"ខ" ចុះថ្ងៃទី ២៦-០១-២០០៤ របស់តុលាការខេត្តតាកែវ ។

២- ទណ្ឌិតឈ្មោះ **នារ៉េ ណារុន** ភេទប្រុស អាយុ ៤៧ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-៣-២០០០ ពីបទបៀតបៀនកេរ្តិ៍ខ្មាស់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំតាមអំណាចសាលក្រមលេខ ២០"ខ" ចុះថ្ងៃទី ១៥-៩-២០០០ របស់តុលាការខេត្តតាកែវ ។

៣- ទណ្ឌិតឈ្មោះ **ទី្វ សុផុន** ភេទប្រុស អាយុ ៣៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-៨-២០០០ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំតាមអំណាចសាលក្រមលេខ ៣៥ "ក" ចុះថ្ងៃទី ៣១-៨-២០០០ របស់តុលាការខេត្តតាកែវ ។

៤- ទណ្ឌិតឈ្មោះ **ស៊ុន ស៊ីថា** ភេទប្រុស អាយុ ៣៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១១-៨-២០០៣ ពីបទបង្ករបួសស្លាប់ដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ខែ តាមអំណាចសាលក្រមលេខ ១៧"ខ" ចុះថ្ងៃទី ១៦-៣-២០០៤ របស់តុលាការខេត្តតាកែវ ។

៥- ទណ្ឌិតឈ្មោះ **គីម ចន្ទាមុន្នី** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ ឆ្នាំ តែទោសនេះត្រូវចែកជាពីរ គឺទោសគុកចំនួន ៣ ខែ សល់ពីនេះត្រូវព្យួរដោយមានរយៈពេលសាកល្បង ៥ ឆ្នាំ ពីបទបង្ករបួសស្នាម តាមអំណាចសាលដីកាលេខ ២៣៨ ចុះថ្ងៃទី ១៣-១០-២០០០ របស់សាលាឧទ្ធរណ៍ ។

៦- ទណ្ឌិតឈ្មោះ **កែវ សុវណ្ណារុធ** ភេទស្រី អាយុ ៤៧ ឆ្នាំត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ ឆ្នាំ តែទោសនេះត្រូវចែកជាពីរ គឺទោសគុកចំនួន ៣ ខែ សល់ពីនេះត្រូវព្យួរដោយមានរយៈពេលសាកល្បង ៥ ឆ្នាំ ពីបទបង្ករបួសស្នាម តាមអំណាចសាលដីកាលេខ ២៣៨ ចុះថ្ងៃទី ១៣-១០-២០០០ របស់សាលាឧទ្ធរណ៍ ។



6/7-

មាត្រា ៥ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល. ០៤១២.០៨៧

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៤

លេខ: ៣៥០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ.ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាឌី តាន់**



7/+

# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៨៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តម្លើងឋានន្តរស័ក្តិជាកិច្ចបច្ឆាមរណៈ ជូន សព +

### ក. តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ

១-ឧត្តមសេនីយ៍ត្រី **ឈួន ញឹម** អត្តលេខ ០០៣៩៧៤

២-ឧត្តមសេនីយ៍ត្រី **ម៉ែន ផេង** អត្តលេខ ០០០១៨៦

### ខ. តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី

១-វរសេនីយ៍ឯក **ស្នួង សុខពាល** អត្តលេខ ០០០៤១៩

4/3

២-វរសេនីយ៍ឯក ថាវ ឌិន អត្តលេខ ០០៤៩៦៣

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៤១២.០៨៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៤

លេខ: ៣៥៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាឌី តាន់**

3/3

# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៨៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៨/១០៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម រ័ត្ន ធីរៈ ជាអគ្គលេខាធិការរង នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ព.រ.ល. ០៤១២.០៨៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៤*

លេខ ៣៤៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវ ឌី តាន់**

ᥤ/₂

# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៩០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ណារ៉ត សុខា** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣ល.០៤១៧.០៩០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៤*

លេខ: ៣៤៩ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ណារី តាន់

2/2

# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៩១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងលោកជំទាវ **ទី សាមីន** ជាទីប្រឹក្សារបស់ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា២:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.០៤១៧.០៩១

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៤*

លេខ: ៣៤៧៦.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ឈាងី តាន់

2/2

# ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០០២

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានលុបឈ្មោះឯកឧត្តម ឈា សុខ អតីតរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានទទួលមរណៈភាពដោយរោគាពាធ ចេញពីក្របខ័ណ្ឌគ្រប់គ្រងរដ្ឋបាល ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ ០៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
ស៊ុយ សែម
ឈឹម តាន់

៣៧៧.០៥០១.០០៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែមករាឆ្នាំ ២០០៥

2/2

# ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០០៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ទិន មីងទី** (WEN MING-TI) សញ្ជាតិដើមចិន កើតថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៦៤ នៅស្រុកជិនជូ ក្រុងតៃប៉ិ កោះតៃវ៉ាន់ ប្រទេសចិន។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

រ.ស.ល. ០៥០១-០០៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៥

លេខ : ០១ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាវ៉ី តាន់**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ

លេខ: ០១ ព.រ.ក

# សេចក្តីសំរេចរួម

## ស្តីពី

## បៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗ របស់មន្ត្រីរាជការ នៃក្រុមនីតិបញ្ញត្តិ

**ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

**ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា**

**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងប្រធាន អនុប្រធានទី១ និង អនុប្រធានទី២ នៃព្រឹទ្ធសភាសំរាប់នីតិកាលទី១
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា
- បានឃើញកំណត់ហេតុសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៣ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធានទី១ និង អនុប្រធានទី២ នៃរដ្ឋសភាសំរាប់នីតិកាលទី៣
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២២១ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សំរាប់អាណត្តិ៣ឆ្នាំ លើកទី៣
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិបញ្ញត្តិ
- យោងតាមការចាំបាច់ក្នុងការរៀបចំបៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការ នៃក្រុមនីតិបញ្ញត្តិ

# សំរេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ :**

បៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗ គឺជាកំរៃជីវភាពប្រចាំខែ ដែលរដ្ឋត្រូវផ្តល់ជូនមន្ត្រីរាជការស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការបំពេញការងារ ។

បៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗរួមមាន :

- បៀវត្សមូលដ្ឋាន
- ប្រាក់បំណាច់មុខងារ
- ប្រាក់បំប៉នផ្គត់ផ្គង់ជីវភាពផ្សេងៗ
- ប្រាក់បំណាច់ទទួលខុសត្រូវ
- ប្រាក់ហានិភ័យ និង ប្រាក់វិភាជន៍គ្រួសារ ។

## ជំពូកទី២
## បៀវត្សមូលដ្ឋាន

**មាត្រា២ :**

បៀវត្សមូលដ្ឋាន គឺជាប្រាក់ប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការសំរាប់ជីវភាពរស់នៅក្នុងនោះមាន : គ្រឿងឧបភោគ បរិភោគ ការស្នាក់នៅ សំលៀកបំពាក់ ការព្យាបាលជំងឺ ។

**មាត្រា៣ :**

បៀវត្សមូលដ្ឋាននៃមន្ត្រីរាជការត្រូវបែងចែកទៅតាមប្រភេទ ឋានន្តរស័ក្តិ និង ថ្នាក់ដែលត្រូវកំណត់ទៅតាមកំរិតនៃសន្ទស្សន៍ដូចខាងក្រោម :

| ប្រ.គ | ថានន្តរស័ក្តិ | ថ្នាក់ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១៤ | ១៣ | ១២ | ១១ | ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| | ក ១ | | | | | | | | | ៤៣៦ | ៤៥៧ | ៤៨២ | ៥០៦ | ៥២៨ | ៥៥០ |
| ក | ក ២ | | | | | ៣៦១ | ៣៧៣ | ៣៨៧ | ៤០២ | ៤១៩ | ៤៣៧ | ៤៥៥ | ៤៦៧ | ៤៧៨ | ៤៨៧ |
| | ក ៣ | ៣១៥ | ៣២៣ | ៣៣១ | ៣៤០ | ៣៤៩ | ៣៥៩ | ៣៦៩ | ៣៨០ | ៣៩០ | ៣៩៩ | ៤០៧ | ៤១៤ | ៤២០ | ៤២៥ |
| | ខ ១ | | | | | | | | | ៣០៨ | ៣២៤ | ៣៤៤ | ៣៦០ | ៣៧៤ | ៣៨៥ |
| ខ | ខ ២ | | | | | ២៥២ | ២៦២ | ២៧២ | ២៨៣ | ២៩៥ | ៣០៦ | ៣១៦ | ៣២៥ | ៣៣៣ | ៣៤០ |
| | ខ ៣ | ២២០ | ២២៥ | ២៣០ | ២៣៦ | ២៤៣ | ២៥១ | ២៥៩ | ២៦៦ | ២៧៣ | ២៧៩ | ២៨៤ | ២៨៩ | ២៩៣ | ២៩៧ |
| | គ ១ | | | | | | | | | ២១២ | ២២៣ | ២៣៥ | ២៤៥ | ២៥៤ | ២៦២ |
| គ | គ ២ | | | | | ១៧៣ | ១៧៨ | ១៨៥ | ១៩៣ | ២០១ | ២០៨ | ២១៥ | ២២២ | ២២៨ | ២៣៣ |
| | គ ៣ | ១៥០ | ១៥៤ | ១៥៨ | ១៦៣ | ១៦៨ | ១៧៤ | ១៧៩ | ១៨៤ | ១៨៨ | ១៩២ | ១៩៥ | ១៩៨ | ២០០ | ២០២ |
| | ឃ ១ | | | | | | | | | ១៤១ | ១៤៩ | ១៥៧ | ១៦៤ | ១៧០ | ១៧៥ |
| ឃ | ឃ ២ | | | | | ១១៣ | ១១៧ | ១២២ | ១២៨ | ១៣៤ | ១៣៩ | ១៤៤ | ១៤៨ | ១៥២ | ១៥៥ |
| | ឃ ៣ | ១០០ | ១០២ | ១០៤ | ១០៦ | ១០៩ | ១១២ | ១១៦ | ១២០ | ១២៣ | ១២៦ | ១២៩ | ១៣១ | ១៣៣ | ១៣៥ |

**មាត្រា៤ :**

តម្លៃឯកតានៃសន្ទស្សន៍សំរាប់អនុវត្តក្នុងតារាងបៀវត្សមន្ត្រីរាជការក្របខ័ណ្ឌនៃក្រុមនីតិប្បញ្ញត្តិមានចំនួន ៣០០៛ ( បីរយរៀលគត់ ) ។

ការកែប្រែតំលៃឯកតានៃសន្ទស្សន៍នេះ ត្រូវធ្វើឡើងដោយសេចក្តីសំរេចរួមរបស់ប្រធានស្ថាប័នទាំងបី ។

**មាត្រា៥ :**

មន្ត្រីកម្មសិក្សាដែលជ្រើសរើសចេញពី សិស្ស និស្សិត ត្រូវបានផ្តល់សន្ទស្សន៍បៀវត្សក្នុងថ្នាក់ទី១៤ នៃឋានន្តរស័ក្តិទី៣ របស់ក្របខ័ណ្ឌនីមួយៗ។

**មាត្រា៦ :**

មន្ត្រីរាជការមានសិទ្ធិទទួលបៀវត្សមូលដ្ឋានបានតែក្នុងល័ក្ខខ័ណ្ឌដូចខាងក្រោម :

១- កំពុងបំពេញសកម្មភាពការងារ

២- កំពុងផ្លាស់ប្តូរកន្លែងធ្វើការនៅក្នុង ឬ ក្រៅប្រទេស

៣- កំពុងធ្វើដំណើរទៅកាន់មុខតំណែង ឬ កំពុងវិលត្រឡប់មកវិញ

៤- កំពុងបំពេញកម្មសិក្សាវិជ្ជាជីវៈ ឬ បច្ចេកទេសតាមតម្រូវការរបស់រដ្ឋ

៥- កំពុងបំពេញកម្មសិក្សាជាដំបូង ដើម្បីតាំងស៊ប់ក្នុងក្របខ័ណ្ឌ។

**មាត្រា៧ :**

សិទ្ធិទទួលនូវបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការ ត្រូវគិតចាប់ផ្តើមពីថ្ងៃចូលបំរើការងារជាស្ថាពរ ដែលទទួលស្គាល់ដោយប្រធានស្ថាប័នសាមី ហើយត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរដល់ក្រសួងស្ថាប័នមានសមត្ថកិច្ច។

**មាត្រា៨ :**

មន្ត្រីរាជការដែលឈប់សំរាកស្របតាមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ និង បទប្បញ្ញត្តិផ្សេងៗ ដែលនៅជាធរមាន មានសិទ្ធិទទួលបៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗ។

**មាត្រា៩ :**

បៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗ ត្រូវផ្តល់ជូនដល់មន្ត្រីរាជការដែលត្រូវចាត់អោយចូលរៀនវគ្គបណ្តុះបណ្តាលបំពាក់បំប៉នវិជ្ជាជីវៈ ឬ បច្ចេកទេសតាមតំរូវការរបស់រដ្ឋស្របតាមក្របខ័ណ្ឌរបស់សាមីខ្លួន។

**មាត្រា១០ :**

ការបញ្ឈប់ផ្តល់បៀវត្សមូលដ្ឋាន ត្រូវធ្វើទៅតាមកំណត់នៃសេចក្តីសំរេចរបស់ប្រធានស្ថាប័ន ក្នុងករណីដូចខាងក្រោមនេះ :

- មន្ត្រីរាជការសុំលាឈប់ពីការងារដោយមានការអនុញ្ញាត
- មន្ត្រីរាជការដែលត្រូវបណ្តេញចេញពីមុខតំណែង

- មន្ត្រីរាជការដែលទទួលមរណភាព
- មន្ត្រីរាជការដែលអវត្តមានគ្មានការអនុញ្ញាត ឬ ហួសរយៈពេលកំណត់
- មន្ត្រីរាជការដែលវិលត្រឡប់មកកាន់ការងារវិញ ហួសរយៈពេលដែលកំណត់ដោយលិខិតបង្គាប់ការ លើកលែងតែករណីស្របច្បាប់ ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច
- មន្ត្រីរាជការដែលអវត្តមានហួសកាលកំណត់ក្នុងបេសកកម្ម ឬ ការឈប់សំរាក លើកលែងតែករណីប្រធានស័ក្តិ ឬ ដោយជម្ងឺ ដែលមានលិខិតបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬ ពីសមត្ថកិច្ចសុខាភិបាល
- មន្ត្រីរាជការដែលមានសាលក្រមរបស់តុលាការបញ្ជាក់ថាជាទណ្ឌិត ។

**<u>មាត្រា១១</u> :**

មន្ត្រីរាជការដែលត្រូវបានដាក់អោយស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សគ្មានសិទ្ធិទទួលបៀវត្សមូលដ្ឋាន ចាប់ពីថ្ងៃកំណត់ដែលមានចែងក្នុងព្រះរាជក្រឹត្យ ឬ សេចក្តីសំរេច ។

**<u>មាត្រា១២</u> :**

មន្ត្រីរាជការដែលត្រូវបានដាក់អោយចូលនិវត្តន៍ គ្មានសិទ្ធិទទួលបៀវត្សមូលដ្ឋានទេ ។

## ជំពូកទី៣
## ប្រាក់បំណាច់មុខងារ

**<u>មាត្រា១៣</u> :**

ប្រាក់បំណាច់មុខងារ គឺជាប្រាក់បន្ថែមទៅលើបៀវត្សមូលដ្ឋានប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការនៅក្នុងប្រភេទ **ក.ខ.គ** និង **ឃ** ហើយដែលកំពុងបំពេញមុខងារក្នុងស្ថាប័ន ។

**<u>មាត្រា១៤</u> :**

ប្រាក់បំណាច់មុខងារត្រូវបានបែងចែកជា ០៥ការិត ទៅតាមរយៈពេល និង បទពិសោធន៍ការងារក្នុងមុខតំណែងនីមួយៗ ដូចខាងក្រោម :

- ការិតទី ៥ សំរាប់បទពិសោធន៍រយៈពេលក្រោម ០៣ឆ្នាំ
- ការិតទី ៤ សំរាប់បទពិសោធន៍រយៈពេលពី ០៣ឆ្នាំ ទៅ ០៦ឆ្នាំ

- កំរិតទី ៣ សំរាប់បទពិសោធន៍រយៈពេលពី ០៦ឆ្នាំ ទៅ ១០ឆ្នាំ
- កំរិតទី ២ សំរាប់បទពិសោធន៍រយៈពេលពី ១០ឆ្នាំ ទៅ ១៦ឆ្នាំ
- កំរិតទី ១ សំរាប់បទពិសោធន៍រយៈពេលលើសពី ១៦ឆ្នាំ

**មាត្រា១៥ :**

ការផ្លាស់ប្តូរកំរិត និង ការផ្តល់ប្រាក់បំណាច់មុខងារ មិនអាចអនុវត្តទៅតាមឆ្នាំកំណត់ដូចមានចែងនៅក្នុងមាត្រា១៤ ជាស្វ័យប្រវត្តិបានទេ គឺត្រូវធ្វើឡើងដោយការវាយតម្លៃពីគណៈកម្មការតំឡើងថ្នាក់ និង មានការយល់ព្រមពីប្រធានស្ថាប័ន។

**មាត្រា១៦ :**

មន្ត្រីរាជការដែលមានមុខតំណែងដូចខាងក្រោម ត្រូវបានទទួលប្រាក់បំណាច់មុខងារប្រចាំខែ ដូចមានចែងនៅក្នុងតារាងខាងក្រោមនេះ :

| ល.រ | មុខងារ | កំរិតទី ៥ | កំរិតទី ៤ | កំរិតទី ៣ | កំរិតទី ២ | កំរិតទី ១ |
|---|---|---|---|---|---|---|
| ០១ | អគ្គនាយក | ៧៣៥.០០០៛០០ | ៧៧៩.០០០៛០០ | ៨២៦.០០០៛០០ | ៨៧៦.០០០៛០០ | ៩២៩.០០០៛០០ |
| ០២ | អគ្គាធិការ | ៧២០.០០០៛០០ | ៧៦៣.០០០៛០០ | ៨០៩.០០០៛០០ | ៨៥៨.០០០៛០០ | ៩១០.០០០៛០០ |
| ០៣ | អគ្គនាយករង | ៦៤៥.០០០៛០០ | ៦៨៤.០០០៛០០ | ៧២៥.០០០៛០០ | ៧៦៩.០០០៛០០ | ៨១៥.០០០៛០០ |
| ០៤ | អគ្គាធិការរង | ៦៣០.០០០៛០០ | ៦៦៨.០០០៛០០ | ៧០៨.០០០៛០០ | ៧៥១.០០០៛០០ | ៧៩៦.០០០៛០០ |
| ០៥ | ប្រធាននាយកដ្ឋាន | ៦២០.០០០៛០០ | ៦៥៨.០០០៛០០ | ៦៩៨.០០០៛០០ | ៧៤១.០០០៛០០ | ៧៨៦.០០០៛០០ |
| ០៦ | អនុប្រធាននាយកដ្ឋាន | ៥០០.០០០៛០០ | ៥៣៨.០០០៛០០ | ៥៧៨.០០០៛០០ | ៦២១.០០០៛០០ | ៦៦៦.០០០៛០០ |
| ០៧ | មន្ត្រីអភិបាល | ៤០០.០០០៛០០ | ៤៣៨.០០០៛០០ | ៤៧៨.០០០៛០០ | ៥២១.០០០៛០០ | ៥៦៦.០០០៛០០ |
| ០៨ | ប្រធានការិយាល័យ | ៤៥០.០០០៛០០ | ៤៨៨.០០០៛០០ | ៥២៨.០០០៛០០ | ៥៧១.០០០៛០០ | ៦១៦.០០០៛០០ |
| ០៩ | អនុប្រធានការិយាល័យ | ៤០០.០០០៛០០ | ៤៣៨.០០០៛០០ | ៤៧៨.០០០៛០០ | ៥២១.០០០៛០០ | ៥៦៦.០០០៛០០ |
| ១០ | ប្រធានផ្នែក | ៣៥០.០០០៛០០ | ៣៨៨.០០០៛០០ | ៤២៨.០០០៛០០ | ៤៧១.០០០៛០០ | ៥១៦.០០០៛០០ |
| ១១ | មន្ត្រីឧបការី | ៣២០.០០០៛០០ | ៣៥៨.០០០៛០០ | ៣៩៨.០០០៛០០ | ៤២១.០០០៛០០ | ៤៦៦.០០០៛០០ |
| ១២ | មន្ត្រីលេខាធិការ | ២៦០.០០០៛០០ | ២៩៨.០០០៛០០ | ៣៣៨.០០០៛០០ | ៣៧១.០០០៛០០ | ៤១៦.០០០៛០០ |
| ១៣ | មន្ត្រីភ្នាក់ងារ | ២៣០.០០០៛០០ | ២៦៨.០០០៛០០ | ៣០៨.០០០៛០០ | ៣២១.០០០៛០០ | ៣៦៦.០០០៛០០ |

**មាត្រា១៧ :**

មន្ត្រីរាជការដែលស្ថិតនៅក្នុងមុខតំណែងណាមួយ ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងនោះ ។

មន្ត្រីរាជការដែលកាន់មុខតំណែងច្រើន ត្រូវអនុញ្ញាតអោយជ្រើសរើសយកប្រាក់បំណាច់មុខងារតែមួយទេ ។

**មាត្រា១៨ :**

ការកែប្រែប្រាក់បំណាច់មុខងារ ត្រូវធ្វើឡើងដោយសេចក្តីសំរេចរួម ។

## ជំពូកទី ៤
## ប្រាក់បំប៉នផ្គត់ផ្គង់ជីវភាពផ្សេងៗ

**មាត្រា១៩ :**

មន្ត្រីរាជការដែលស្ថិតក្នុងក្របខ័ណ្ឌនៃក្រុមនីតិប្បញ្ញត្តិត្រូវបានទទួលប្រាក់បំប៉នផ្គត់ផ្គង់ជីវភាពផ្សេងៗ ប្រចាំខែចំនួន ២៥០.០០០រ០០ ( ពីររយហាសិបពាន់រៀលគត់) ។

ការកែប្រែប្រាក់បំប៉នផ្គត់ផ្គង់ជីវភាពផ្សេងៗ ត្រូវធ្វើឡើងដោយសេចក្តីសំរេចរួម ។

## ជំពូកទី៥
## ប្រាក់បំណាច់ទទួលខុសត្រូវ

**មាត្រា២០ :**

ប្រាក់បំណាច់ទទួលខុសត្រូវ ជាប្រាក់បំណាច់បន្ថែមប្រចាំខែសំរាប់ផ្តល់ជូនមន្ត្រីរាជការ ដែលមានការតែងតាំងឋានៈ និង មានតួនាទីដឹកនាំក្នុងមុខតំណែងពិតប្រាកដ ។

**មាត្រា២១ :**

មន្ត្រីរាជការចាប់ពីឋានៈអគ្គនាយកចុះមកដល់ប្រធានផ្នែក ត្រូវបានទទួលប្រាក់បំណាច់ទទួលខុសត្រូវបន្ថែមដូចមានចែងនៅក្នុងតារាងខាងក្រោមនេះ :

| ល.រ | មុខងារ | ចំនួនទឹកប្រាក់ |
|---|---|---|
| ០១ | អគ្គនាយក | ២៦១.០០០រ០០ |
| ០២ | អគ្គាធិការ | ២៥១.០០០រ០០ |
| ០៣ | អគ្គនាយករង | ២៤១.០០០រ០០ |
| ០៤ | អគ្គាធិការរង | ២៣១.០០០រ០០ |
| ០៥ | ប្រធាននាយកដ្ឋាន | ២២១.០០០រ០០ |
| ០៦ | អនុប្រធាននាយកដ្ឋាន | ២០១.០០០រ០០ |
| ០៧ | ប្រធានការិយាល័យ | ១៨០.០០០រ០០ |
| ០៨ | អនុប្រធានការិយាល័យ | ១៦០.០០០រ០០ |
| ០៩ | ប្រធានផ្នែក | ១៤០.០០០រ០០ |

**មាត្រា២២ :**

ការកែប្រែប្រាក់បំណាច់ទទួលខុសត្រូវ ត្រូវធ្វើឡើងដោយសេចក្តីសំរេចរួម ។

**មាត្រា២៣ :**

មន្ត្រីដែលត្រូវបានតែងតាំងអោយមានឋានៈស្មើ គ្មានសិទ្ធិទទួលប្រាក់បំណាច់ទទួលខុសត្រូវឡើយ លើកលែងតែក្នុងករណីដែលសាមីជនបំពេញមុខការពិសេសចាំបាច់ ហើយសំរេចដោយប្រធានស្ថាប័នតាមសំណើរបស់អគ្គលេខាធិការ ។

## ជំពូកទី៦

## ប្រាក់ហានិភ័យ

**មាត្រា២៤ :**

ប្រាក់ហានិភ័យ គឺជាប្រាក់ប្រចាំខែសំរាប់ផ្តល់ជូនដល់មន្ត្រីរាជការទាំងឡាយដែលត្រូវអោយទៅបំរើការងារ ឬ បំរើការងារនៅក្នុងមុខងារ ឬ ទីកន្លែងដែលមានគ្រោះថ្នាក់ ជម្ងឺឆ្លង ការងារប៉ះពាល់សុខភាព ដូចជាកន្លែងក្តៅ សើម មានធូលីច្រើន ចំហាយជាតិពុល ឬ ជាតិគីមី សម្លេងខ្លាំងខ្លាំង ក្លិនស្អុយ និង តំបន់គ្រុនចាញ់ ។

**មាត្រា២៥ :**

ប្រាក់ហានិភ័យមានពីរគឺ :

១- ប្រាក់ប៉ះពាល់សុខភាព

២- ប្រាក់តំបន់

មុខងារដែលប៉ះពាល់សុខភាព និង តំបន់ហានិភ័យព្រមទាំងប្រាក់ហានិភ័យនឹងត្រូវកំណត់ដោយសេចក្តីសំរេចរួមមួយដោយឡែក ។

## ជំពូកទី៧
## ប្រាក់វិភាជន៍គ្រួសារ

**មាត្រា២៦ :**

ប្រាក់វិភាជន៍គ្រួសារ គឺជាប្រាក់ប្រចាំខែដែលត្រូវផ្តល់ជូនមន្ត្រីរាជការជាមេគ្រួសារ សំរាប់ប្រពន្ធ និង កូនស្របច្បាប់ នៅក្នុងបន្ទុក ។

ប្រាក់វិភាជន៍សំរាប់កូនអាចបន្តផ្តល់ជូនរហូតដល់អាយុ ២១ឆ្នាំ ក្នុងករណីមានលិខិតបញ្ជាក់ការសិក្សា ។

**មាត្រា២៧ :**

ប្រាក់វិភាជន៍គ្រួសារ ត្រូវផ្តល់ជូនមន្ត្រីរាជការនៅក្នុងគ្រប់ករណី ដែលសាមីខ្លួននៅមានសិទ្ធិទទួលបៀវត្សមូលដ្ឋាន ។

មន្ត្រីរាជការដែលជាមេគ្រួសារ ត្រូវទទួលខុសត្រូវចំពោះព័ត៌មានស្តីពីស្ថានភាពគ្រួសារ ទាក់ទងនឹងប្រាក់វិភាជន៍គ្រួសារ ។

**មាត្រា២៨ :**

ប្រាក់វិភាជន៍គ្រួសារប្រចាំខែត្រូវផ្តល់ជូនដូចខាងក្រោម :

| ល.រ | ប្រាក់វិភាជន៍គ្រួសារ | ចំនួនទឹកប្រាក់ |
|---|---|---|
| ០១ | ប្រពន្ធ | ៣.០០០រៀល |
| ០២ | កូន | ២.៥០០រៀល |

**មាត្រា២៩ :**

ការកែប្រែប្រាក់វិភាជន៍គ្រួសារ ត្រូវកំណត់ដោយសេចក្ដីសំរេចរួម ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា៣០ :**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣១ :**

អគ្គលេខាធិការព្រឹទ្ធសភា អគ្គលេខាធិការរដ្ឋសភា និង អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤

| | | |
|---|---|---|
| **ប្រធានព្រឹទ្ធសភា** | **ប្រធានរដ្ឋសភា** | **ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ** |
| **ហត្ថលេខា និងត្រា** | **ព្រះហស្តលេខា និងត្រា** | **ហត្ថលេខា និងត្រា** |
| **ជា ស៊ីម** | **នរោត្តម រណឫទ្ធិ** | **ប៊ិន ឈិន** |

លេខ: ៣៤៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**

**កន្លែងទទួល**

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការព្រឹទ្ធសភា
- អគ្គលេខាធិការរដ្ឋសភា
- អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០១ អនក្រ.តត

## អនុក្រឹត្យ
### ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តក្រចេះ

**ស ម្រេ ច**

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន វៀតណាមចំនួន ០៣ រូប ដែលបានបរិច្ចាគធនធាន ជួយកសាងបណ្តាញអគ្គិសនី ពីច្រកទ្វារព្រំដែនស្នួល ដល់ទីរួមស្រុកស្នួល មានប្រវែង ១៨.៧១ គ.ម ដូចមានរាយនាមខាងក្រោម ÷

១-លោក **ជិញ លឿងសឺន** **Trịnh Lƣõng Sỏn** លេខាបក្សស្រុកឡុកនិញ

២-លោក **ហ៊ុញ ហ៊្វីយុង** **Huỳnh Phí Dũng** ប្រធានសមាគមវិនិយោគ និង អភិវឌ្ឍន៍បណ្តាក្រុមហ៊ុន

៣-លោក **តាំង ធីវហា** **Tăng Thiêu Hà** នាយករោងចក្រកែឆ្នៃកៅស៊ូ សារុនទីមិច

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ០៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

&&&&&

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តក្រចេះ

**ស ម្រេ ច**

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សរឫទ្ធិ** ជូនអង្គភាព និង ថ្នាក់ដឹកនាំខេត្ត ដែលមានស្នាដៃល្អ ក្នុងការលើកកំពស់ចំណងមិត្តភាព សាមគ្គីភាព និង សហប្រតិបត្តិការលើវិស័យ កសិកម្ម និង សេដ្ឋកិច្ច រវាងខេត្តក្រចេះនៃព្រះរាជាណាចក្រកម្ពុជា ជាមួយខេត្តប៊ិញភឿក និង ខេត្តប៊ិញយឿង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងរយៈពេលកន្លងមក ដូចមានរាយនាមខាងក្រោម ÷

១- **គណៈកម្មាធិការប្រជាជនខេត្តប៊ិញភឿក** ( **UBND tỉnh Bình Phuóc** )

២- **គណៈកម្មាធិការប្រជាជនខេត្តប៊ិញយឿង** ( **UBND tỉnh Bình DUONG** )

៣-លោក **ង្វៀន វៀតគឿង** **Nguyễn Việt Cuống** អនុប្រធានគណៈកម្មាធិការបក្ស

៤-លោក **ង្វៀន វ៉ាន់ថរ** **Nguyễn Văn Thỏa** អនុប្រធានគណៈកម្មាធិការប្រជាជនខេត្ត

៥-លោក **ង្វៀន ហ៊ីហ្វុង** **Nguyễn Huy Phong** អនុប្រធានគណៈកម្មាធិការប្រជាជនខេត្ត

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០៣ អនក្រ.តត

# អនុក្រឹត្យ

**ស្តីពី**

**ការសំរួល និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

## សម្រេច

**មាត្រា ១ .—**

ត្រូវបានសំរួលភារកិច្ចលោក **សាមុត ឡៀន** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៧ ពីអភិបាល ស្រុកកៀនស្វាយ មកជាអភិបាលរង ស្រុកកៀនស្វាយ ខេត្តកណ្តាល ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ ដដែល ។

**មាត្រា ២ .—**

ត្រូវបានប្រគល់ភារកិច្ចជូនលោក **ម៉ុំ មិន** ឋានន្តរសក្តិ វរៈសេនីយ៍ត្រី ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ឱ្យបកទទួលភារកិច្ចជាអភិបាល ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

**មាត្រា ៣ .—**

លោក **ម៉ុំ មិន** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវ ដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៤ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ .—**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការសំរួល និងតែងតាំងមុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

## សម្រេច

**មាត្រា ១ .—**

ត្រូវបានសំរួលភារកិច្ចលោក **ទឹម ដារ៉េត** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ ពីអភិបាល ស្រុករតនមណ្ឌល មកជាអភិបាលរង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ ដដែល ។

**មាត្រា ២ .–**

ត្រូវបានតែងតាំងលោក **កែប ផេខលី** ឋានន្តរសក្តិ អនុបន្ត្រី ថ្នាក់លេខ ១០ ជាអភិបាល ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ។

**មាត្រា ៣ .–**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ .–**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ . ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៤ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៥ អនក្រ.តត

## អនុក្រឹត្យ

ស្តីពី

## ការសំរួល និងតែងតាំងមុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

## សម្រេច

**មាត្រា ១ .–**

ត្រូវបានសំរួលភារកិច្ចលោក **សំ ថា** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៣ ពីអភិបាល ស្រុកវិដ្ឋល មកជាអភិបាលរង ស្រុកវិដ្ឋល ខេត្តស្វាយរៀង ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ ដដែល ។

**មាត្រា ២ .–**

ត្រូវបានតែងតាំងលោក **អ៊ុក ប៊ុណ្ណា** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១១ ជាអភិបាល ស្រុកវិដ្ឋល ខេត្តស្វាយរៀង ។

**មាត្រា ៣ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ .-**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ . ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៤ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការសំរួល និងតែងតាំងមុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

## សម្រេច

**មាត្រា ១ .–**

ត្រូវបានសំរួលភារកិច្ចលោក **ពុធ សារុន** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៧ ពីអភិបាល ស្រុកពាមជរ មកជាអភិបាលរង ស្រុកពាមជរ ខេត្តព្រៃវែង ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ ដដែល ។

**មាត្រា ២ .–**

ត្រូវបានតែងតាំងលោក **អាង ឈឿន** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ ជាអភិបាល ស្រុកពាមជរ ខេត្តព្រៃវែង ។

**មាត្រា ៣ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ .—**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ . ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>ចម្លងជូន</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៤ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការសំរួល និងប្រគល់ភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងការអនុវត្តនី ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

## សម្រេច

**មាត្រា ១ .—**

ត្រូវបានសំរួលភារកិច្ចលោក **ឆៅ ម្រង់** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៤ ពីអភិបាល ស្រុកបាណន់ មកជាអភិបាលរង ស្រុកបាណន់ ខេត្តបាត់ដំបង ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ ដដែល ។

**មាត្រា ២ .—**

ត្រូវបានប្រគល់ភារកិច្ចជូនលោក **តូច ស៊ុនណារ៉ា** ឋានន្តរសក្តិ អនុសេនីយ៍ឯក ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ឱ្យមកទទួលភារកិច្ចជាអភិបាល ស្រុកបាណន់ ខេត្តបាត់ដំបង ។

**មាត្រា ៣ .—**

លោក **តូច ស៊ុនណារ៉ា** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៤ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ .—**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៨ អនក្រ.តត

# អនុក្រឹត្យ

ស្តីពី

## ការសំរួល និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

## សម្រេច

**មាត្រា ១ .—**

ត្រូវបានសំរួលភារកិច្ចលោក **ខៀវ សំអាត** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៥ ពីអភិបាល ស្រុកល្វាឯម មកជាអភិបាលរង ស្រុកល្វាឯម ខេត្តកណ្តាល ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ ដដែល ។

**មាត្រា ២ .—**

ត្រូវបានប្រគល់ភារកិច្ចជូនលោក **ចេទ សារ៉េន** ឋាននន្តរសក្តិ អនុសេនីយ៍ឯក ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ឱ្យមកទទួលភារកិច្ចជាអភិបាល ស្រុកល្វាឯម ខេត្តកណ្តាល ។

**មាត្រា ៣ .—**

លោក **ចេទ សារ៉េន** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវ ដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៤ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ .—**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៧ អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

## ការសំរួល និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងការអនុវត្តនី ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .—**

ត្រូវបានសំរួលភារកិច្ចលោក **ជួប ខុន** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ ពីអភិបាល ខណ្ឌ៧មករា មកជាអភិបាលរង ខណ្ឌ៧មករា ក្រុងភ្នំពេញ ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ ដដែល ។

**មាត្រា ២ .—**

ត្រូវបានប្រគល់ភារកិច្ចជូនលោក **ស្រ៊ុន ស្រ៊ន់** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យមកទទួលភារកិច្ចជាអភិបាល ខណ្ឌ៧មករា ក្រុងភ្នំពេញ ។

**មាត្រា ៣ .—**

លោក **ស្រ៊ុន ស្រ៊ន់** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិត នៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៤ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ .—**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការសំរួល និងតែងតាំងមុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .–**

ត្រូវបានសំរួលភារកិច្ចលោក **នុច សារុន** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៥ ពីអភិបាល ខណ្ឌឫស្សីកែវ មកជាអភិបាលរង ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ ដដែល ។

**មាត្រា ២ .–**

ត្រូវបានតែងតាំងមុខតំណែងលោក **ឃ្លាំង ហួត** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ ជាអភិបាល ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។

**មាត្រា ៣ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ .—**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ . ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>ចម្លងជូន</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៤ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២២ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងឋានន្តរស័ក្តិនាយនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានា នូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកស្រី **ជា រដ្ឋា** អត្តលេខ ៥៤៨៨៨ ជានាយនគរបាលជាតិជាន់ខ្ពស់នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០០៥*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ២*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្តល់មេដាយការពារ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

**ស ម្រេ ច**

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយការពារ** តាមលំដាប់ថ្នាក់ជូនកងឯកភាព និងបុគ្គល ចំណុះកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដែលមានស្នាដៃល្អ ក្នុងការបំរើជាតិ មាតុភូមិ ដូចមានរាយនាមខាងក្រោម ៖

**ក-**<u>**មេដាយមាសការពារ**</u> :

**-ចំពោះកងឯកភាព :**

១.ការិយាល័យប្រតិបត្តិការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស

២.សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថកំបូល

៣.បញ្ជាការដ្ឋានកងអន្តរាគមន៍រថពាសដែក កងរាជអាវុធហត្ថលើផ្ទៃប្រទេស

៤.បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តឧត្តរមានជ័យ

៥.បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តក្រចេះ

៦.បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបាត់ដំបង

៧.បញ្ជាការដ្ឋានកងរាជអាវុធហត្ថស្រុកអូររាំងឪ ខេត្តកំពង់ចាម

- ចំពោះបុគ្គល :

១. វរសេនីយ៍ឯក **ស្រាក់ សិទ្ធិ** អត្តលេខ ០០១ ១៦១ នាយសេនាធិការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស

២. វរសេនីយ៍ឯក **ជា គីមឡុង** អត្តលេខ ០០១ ១៣៤ នាយសេនាធិការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៣. វរសេនីយ៍ឯក **អ៊ុង សារ៉ាន់** អត្តលេខ ០០២ ៥៤១ នាយសេនាធិការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៤. វរសេនីយ៍ឯក **ស៊ិន សុជាន្នី** អត្តលេខ ០០១ ៨៥២ នាយការិយាល័យកណ្តាលស្រាវជ្រាវ

៥. វរសេនីយ៍ឯក **អ៊ន សុខុន** អត្តលេខ ០០៥ ១៨១ នាយខុទ្ទកាល័យកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៦. វរសេនីយ៍ឯក **គួច ស៊ីតិន** អត្តលេខ ០០២ ៥៦៨ នាយការិយាល័យប្រតិបត្តិការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស

៧. វរសេនីយ៍ឯក **ឃួន វណ្ណរ៉េ** អត្តលេខ ០០២ ៥៥០ នាយការិយាល័យភស្តុភារ កងរាជអាវុធហត្ថលើផ្ទៃប្រទេស

៨. វរសេនីយ៍ឯក **គួច តារា** អត្តលេខ ០០០ ៨៥៦ នាយការិយាល័យហ្វឹកហ្វឺន កងរាជអាវុធហត្ថលើផ្ទៃប្រទេស

៩. វរសេនីយ៍ឯក **ម៉ោម នាង** អត្តលេខ ០០២ ៥៦៣ នាយការិយាល័យបច្ចេកទេសសំភារៈ

១០. វរសេនីយ៍ឯក **ទ៉ា ស៊ុនតីរ៉េម** អត្តលេខ ០០៥ ១៦១ នាយការិយាល័យហិរញ្ញវត្ថុ កងរាជអាវុធហត្ថលើផ្ទៃប្រទេស

១១. វរសេនីយ៍ឯក **ជួង សារ៉ែន** អត្តលេខ ០០២ ៥៤៤ នាយកសាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថកំបូល

១២. វរសេនីយ៍ទោ **ខួន សារឹម** អត្តលេខ ០០៥ ១៦៩ នាយរងការិយាល័យឃោសនា-ពតិមាន កងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៣. វរសេនីយ៍ទោ **សួ សុវណ្ណឌី** អត្តលេខ ០០៥ ១៧៨ មេបញ្ជាការកងអន្តរាគមន៍ថ្មើរជើង

១៤. វរសេនីយ៍ទោ **យ៉ែម ចំនួឌី** អត្តលេខ ០០៥ ១៧៥ មេបញ្ជាការកងអន្តរាគមន៍យានយន្ត

១៥. វរសេនីយ៍ទោ **វង្ស ធី** អត្តលេខ ០០៥ ១៨៥ មេបញ្ជាការរងនិងជានាយសេនាធិការកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ

១៦. វរសេនីយ៍ទោ **ស៊ិន សម្បត្តិ** អត្តលេខ ០០២ ៦០៣ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ

១៧. វរសេនីយ៍ទោ **គីម ជូ** អត្តលេខ ០០៣ ៧៣៣ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ

១៨. វរសេនីយ៍ទោ **ស្រាក់ សោភ័ណ្ឌ** អត្តលេខ ០០២ ៦២៥ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តបាត់ដំបង

១៩. វរសេនីយ៍ទោ **ង៉ុន សារ៉ែន** អត្តលេខ ០០៤ ៥៥៩ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តបាត់ដំបង

២០. វរសេនីយ៍ទោ **សោម ជិន** អត្តលេខ ០០៥ ១៥៦ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តបាត់ដំបង

២១. វរសេនីយ៍ទោ **ឪ ឌី** អត្តលេខ ០០៥ ១៨៤ មេបញ្ជាការរង និងជានាយសេនាធិការកងរាជអាវុធហត្ថក្រុងព្រះសីហនុ

២២. វរសេនីយ៍ទោ **ឡាក់ ឈាង** អត្តលេខ ០០២ ៥៣៨ មេបញ្ជាការរង និងជានាយសេនាធិការកងរាជអាវុធហត្ថខេត្តកំពង់ចាម

២៣. វរសេនីយ៍ទោ **អ៊ុច សាន** អត្តលេខ ០០២ ៥៧១ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តកំពង់ចាម

២៤. វរសេនីយ៍ទោ **ឈាង សុខ** អត្តលេខ ០០២ ៥៧២ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តកំពង់ចាម

២៥. វរសេនីយ៍ទោ **ម៉ែម ពិចិត្រ** អត្តលេខ ០១២ ៤៧៩ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តកំពង់ចាម

២៦. វរសេនីយ៍ទោ **ជាំ ជារ៉ាលីន** អត្តលេខ ០០៤ ២០៧ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តកំពង់ចាម

២៧. វរសេនីយ៍ទោ **ចាន់ ចាន់ធឿន** អត្តលេខ ០០៣ ៦០៧ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តកំពត

២៨. វរសេនីយ៍ទោ **នេត** **វណ្ណា** អត្តលេខ ០១២ ៥៦១ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តកំពត

២៩. វរសេនីយ៍ទោ **ម៉ៅ** **រិទ្ធី** អត្តលេខ ០០១ ៣៥០ មេបញ្ជាការរង និងជានាយសេនាធិការកងរាជអាវុធហត្ថខេត្តក្រចេះ

៣០. វរសេនីយ៍ទោ **ឆៀ** **គៀត** អត្តលេខ ០០២ ៥៣៦ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តក្រចេះ

៣១. វរសេនីយ៍ទោ **ស៊ិន** **លី** អត្តលេខ ០០២ ៥៤៣ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តក្រចេះ

៣២. វរសេនីយ៍ទោ **សាន់** **សារិត** អត្តលេខ ០០២ ៦១៤ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តក្រចេះ

៣៣. វរសេនីយ៍ទោ **ស៊ាង** **វណ្ណដន** អត្តលេខ ០០៣ ១៣៣ មេបញ្ជាការរង និងជានាយសេនាធិការកងរាជអាវុធហត្ថក្រុងប៉ៃលិន

៣៤. វរសេនីយ៍ទោ **សម** **ច័យ** អត្តលេខ ០០៥ ១៩៧ មេបញ្ជាការរងកងរាជអាវុធហត្ថក្រុងប៉ៃលិន

៣៥. វរសេនីយ៍ទោ **ចាន់** **សោភ័ណ្ឌភា** អត្តលេខ ០០៥ ១៩៨ មេបញ្ជាការរងកងរាជអាវុធហត្ថក្រុងប៉ៃលិន

៣៦. វរសេនីយ៍ទោ **ស៊ឹម** **សឿន** អត្តលេខ ០០២ ៦២៣ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តតាកែវ

៣៧. វរសេនីយ៍ទោ **ឆាវ** **ស៊ីផុន** អត្តលេខ ០០៥ ១៩៤ មេបញ្ជាការរង និងជានាយសេនាធិការកងរាជអាវុធហត្ថខេត្តស្ទឹងត្រែង

៣៨. វរសេនីយ៍ត្រី **អ៊ី** **ថាវី** អត្តលេខ ០១២ ៤០៤ នាយផ្នែកប្រេងឥន្ធនៈ ការិយាល័យភស្តុភារកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៣៩. វរសេនីយ៍ត្រី **ជា** **អេងឃ៊ុង** អត្តលេខ ០១២ ៣៩៥ មេបញ្ជាការកងវរសេនាតូចអន្តរាគមន៍ការពារលេខ ១៤៧

៤០. វរសេនីយ៍ត្រី **សរ** **សោភ័ណ្ឌ** អត្តលេខ ០១២ ៤៤៨ មេបញ្ជាការកងអន្តរាគមន៍ការពារគោលដៅលេខ ១៥៦

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក ***Kim Jung Wook*** អគ្គនាយកអង្គការ ***Lamp for Mercy*** នៃសាធារណរដ្ឋកូរ៉េ ដែលបានផ្តល់អំណោយ ជាម៉ាស៊ីនកុំព្យូទ័រ ដល់អគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ សំរាប់បើកវគ្គបណ្តុះបណ្តាលជំនាញពតិមានវិទ្យា ព្រមទាំងផ្តល់ថវិកាឧបត្ថម្ភដល់វគ្គបណ្តុះបណ្តាលជាច្រើនវគ្គកន្លងមក និងផ្តល់អំណោយជាស្បៀង និង សម្ភារៈ ជាច្រើនសន្ធឹកសន្ធាប់ ដល់កងយោធពលខេមរភូមិន្ទ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបាន លទ្ធផលល្អ ។ ៚

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូននាយកតំណាងអង្គការ *KOICA* និង *KOWACO* ដែលមានស្នាដៃល្អក្នុងការចូលរួមសហការជួសជុលអាងទឹក តាមោក ស្រុកពញាឮ ខេត្តកណ្តាល ក្រោមគំរោងជំនួយឥតសំណង របស់រដ្ឋាភិបាល នៃ សាធារណរដ្ឋកូរ៉េ ចំណាយអស់ទឹកប្រាក់ចំនួន ១.៣៦៩.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម :-

១-លោក *CHO KYU CHAN* នាយកតំណាងអង្គការ *KOICA* ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
២-លោក *CHOI BYOUNG-SEUB* នាយកតំណាងអង្គការ *KOWACO* ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបាន លទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៥
**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

D.89

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១៧ អនក្រ.តត.

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

**សម្រេច**

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ទី យុគ្គា** ជាអគ្គនាយករងបច្ចេកទេស របស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០១ សសរ

## សេចក្តីសំរេច
## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## ស ំ រេ ច

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជាជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមកិច្ចប្រជុំពិសេសនៃថ្នាក់ដឹកនាំអាស៊ាន ស្តីពីផលអាក្រក់នៃការរំជួយផែនដី និងព្យុះរលកសមុទ្រ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុង ហ្សាកាតា សាធារណរដ្ឋឥណ្ឌូណេស៊ី ចាប់ពីថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០០៥ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ [illegible]

# ប្រកាស

## ស្តីពី

## ការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
## របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០០៤

## ស ម្រេ ច

**ប្រការ ១.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើនិងបញ្ជាក់ដោយសវនកម្មប្រចាំឆ្នាំ ហើយផ្ញើមកធនាគារជាតិនៃកម្ពុជាអោយបានមុនថ្ងៃទី ៣១ ខែមិនា នៃឆ្នាំប្រតិទិននីមួយៗ ។ ស្នងការគណនីឯករាជ្យប្រតិស្រុតត្រូវធ្វើសវនកម្ម និង ផ្តល់មតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ២.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវបានបញ្ជាក់ដោយសវនកម្មស្របតាមខ្នីមសារដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយនេះ ។

**ប្រការ ៣.-**

របាយការណ៍ និង គណនីដែលត្រូវចេញផ្សាយដូចមានក្នុងគោលការណ៍ណែនាំ ត្រូវចាប់ផ្ដើមពីឆ្នាំ ២០០៥ នេះតទៅ ហើយមិនត្រូវយឺតជាងថ្ងៃទី ៣០ ខែមិថុនា នៃឆ្នាំប្រតិទិនទីមួយៗ ។ របាយការណ៍ និង គណនីដែលបានចេញផ្សាយត្រូវផ្ដល់ជូនអតិថិជន និង សាធារណជន ។

**ប្រការ ៤.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុណា ដែលមិនបានអនុវត្តតាមបទបញ្ជានេះត្រូវទទួលរងការពិន័យស្របតាមមាត្រា៥២នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៥.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៦.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៤

ទេសាភិបាល

ជា ចាន់តូ

**<u>កន្លែងទទួល</u>**

- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្ដីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្ដីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

**គោលការណ៍ណែនាំ**

ប្រកាសលេខ ធ ៧-០៤-២០៤ ប្រក
ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៤

## គោលការណ៍សំរាប់ធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុមីក្រូដែលត្រូវបញ្ចូលនៅក្នុង របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសំរាប់ផ្សព្វផ្សាយជាសាធារណៈ

ធនាគារត្រូវបង្ហាញព័ត៌មានដូចខាងក្រោម :

**១. របាយការណ៍របស់នាយកក្រុមប្រឹក្សាភិបាល**

- បរិដ្ឋានអាជីវកម្មទូទៅ
- របាយការណ៍សង្ខេបនៃប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ
- បង្ហាញដោយសង្ខេបពីផលិតផលថ្មីដែលធ្វើការឧទ្ទេសនាម ប្រសិនបើមាន
- សមត្ថភាពក្នុងការគោរពទៅតាមបទបញ្ញត្តិធនាគារជាតិ និងសកម្មភាពផ្សេងៗ
- ជំហានដែលបានអនុវត្តដើម្បីពង្រឹងប្រតិបត្តិការនិងជំហររបស់ធនាគារ
- គោលដៅនិងកិច្ចសន្យារបស់ក្រុមប្រឹក្សាភិបាល

**២. រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាភិបាល**

- ការបែងចែកភារកិច្ចនិងការទទួលខុសត្រូវនៅក្នុងធនាគារ
- ការរាយការណ៍និងការគ្រប់គ្រងការងារ

**៣. របាយការណ៍របស់ក្រុមប្រឹក្សាភិបាល**

- របាយការណ៍គណៈគ្រប់គ្រង
- សកម្មភាពចំបងៗនៅក្នុងឆ្នាំ

**៤. គោលនយោបាយនិងគោលការណ៍សំរាប់អភិបាលកិច្ចសាជីវកម្ម**

- ការជ្រើសរើសគណៈគ្រប់គ្រង
- ក្រុមប្រឹក្សាភិបាល
    - ✓ សមាសភាពក្រុមប្រឹក្សាភិបាល
    - ✓ ប្រវត្តិសង្ខេបក្រុមប្រឹក្សាភិបាល
    - ✓ ការប្រជុំក្រុមប្រឹក្សាភិបាល

- ការត្រួតពិនិត្យផ្ទៃក្នុង
- ការគ្រប់គ្រងហានិភ័យ
- ក្រមសីលធម៌
- ឯករាជ្យភាពនិងតម្លាភាព

**៥. ការពិពណ៌នាពីអាជីវកម្ម**

- សកម្មភាពចំបងៗរបស់ធនាគារ
- បេសកកម្មនិងទស្សនៈវិស័យ
- ទស្សនៈវិទ្យារបស់ធនាគារ
  - ✓ អតិថិជន
  - ✓ និយោជិក
  - ✓ បរិដ្ឋាន សង្គម និង សហគមន៍
  - ✓ ភាគទុនិក

**៦. សន្ទស្សន៍ហិរញ្ញវត្ថុ ( សូចនាករសំខាន់ៗ )**

- លទ្ធភាពរកចំណេញ
- សង្ខេបតារាងតុល្យការ
- អនុបាតហិរញ្ញវត្ថុ
- ជំពូកផ្សេងៗ ( ភាពលាភ ការគ្រប់គ្រងដើមទុន)

**៧. ការវិភាគលទ្ធផល ( សូចនាករសំខាន់ៗ )**

- ការវិភាគលំអិតជំពូកនីមួយៗនៃប្រតិបត្តិការសំខាន់ៗ

**៨. គោលដៅប្រតិបត្តិការអាជីវកម្ម**

- ទស្សនៈវិស័យហិរញ្ញវត្ថុ
- ទស្សនៈវិស័យអតិថិជន
- ទស្សនៈវិស័យនៃដំណើរការត្រួតពិនិត្យផ្ទៃក្នុង
- ការអភិវឌ្ឍន៍ធនធានមនុស្ស
- ផែនការអាជីវកម្មសំខាន់ៗសំរាប់ឆ្នាំក្រោយ

**៩. គោលនយោបាយគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ**

- ហានិភ័យប្រតិបត្តិការ

- ហានិភ័យឥណទាន
  - ✓ ឥណទានមិនដំណើរការ
  - ✓ បំណុលកែលំអឡើងវិញ
  - ✓ ហានិភ័យពីការប្រមូលផ្តុំឥណទាន ( ហានិភ័យឥណទានធំៗ)
  - ✓ ហានិភ័យពីការថយចុះតំលៃនៃវត្ថុបញ្ចាំ
- ហានិភ័យទីផ្សារ
  - ✓ ហានិភ័យពីការប្តូររូបិយប័ណ្ណបរទេស
  - ✓ ហានិភ័យអត្រាការប្រាក់
  - ✓ ហានិភ័យសាច់ប្រាក់ងាយស្រួល

**១០. ការអះអាងរបស់គណៈគ្រប់គ្រងចំពោះរបាយការណ៍ហិរញ្ញវត្ថុ**

**១១. របាយការណ៍របស់សវនករឯករាជ្យ**

**១២. គតិយុត្តស្តីពីការកាន់កាប់សន្និកបុរេ ( បរិមាណ )**

**១៣. របាយការណ៍ហិរញ្ញវត្ថុរួមទាំងកំណត់សំគាល់ចំពោះរបាយការណ៍ហិរញ្ញវត្ថុ**

**១៤. ភាគីតំណាងរបស់ធនាគារ ( សាខាតំណាងនិងភាគីតំណាងអន្តរជាតិ )**

- សាខាតំណាងនិងភាគីតំណាងអន្តរជាតិ

**១៥. ការផ្លាស់ប្តូរសំខាន់ៗនៅក្នុងឆ្នាំ**

**១៦. របាយការណ៍ហិរញ្ញវត្ថុសង្ខេបរយៈពេលបីឆ្នាំ**

- ការពិនិត្យមើលជារួម

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number: B-7-04-204 Pro Kor

# Prakas

## On

## Annual Audit of Financial Statements of Banks And Financial Institutions

The Governor of the National Bank of Cambodia

With reference to the Constitution of the Kingdom of Cambodia;

- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996 promulgating the Law on the Organization and conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999 promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/0904/244 of 7 September 2004 on the appointment of His Excellency Chea Chanto as Governor of the National Bank of Cambodia;
- Pursuant to the agreement reached at the meeting of the senior officials of the NBC on 28 December 2004

## Decides

**Article 1.**

Banks and Financial Institutions are required to produce annual audited financial statements and submit to National Bank of Cambodia no later than 31 March of each calendar year. Authorized external auditors are required to audit and give an opinion on financial statements of banks and financial institutions.

**Article 2.**

Banks and financial institutions must produce their annual financial reports to be audited in accordance to the appendixes attached.

**Article 3.**

Reports and accounts stipulated as per attached guideline shall be published starting from 2005 and must be no later than June 30 of each calendar year. Published reports and accounts shall be readily available to customers and the public.

**Article 4.**

Banks and Financial Institutions that are not compliant with this regulation will be penalized according to article 52 of the Law on Banking and Financial Institutions.

**Article 5.**

The General Direction, the General Secretariat, the General Inspection, the General Cashier, all Departments of the National Bank of Cambodia, and all Banks and Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article 6.**

This Prakas shall have effect from the signing date.

Phnom Penh, 29 December, 2004

**The Governor**

**Signed and sealed: Chea Chanto**

cc - The Members of the Board of Directors
The parties concerned as stated in Article 5
- File
- CM "for info"
- Administration of CM
"for publication in the National Gazette"

Guideline attached to
Prakas No.B7-04-204 Prokor
date December 29, 2004

# GUIDELINES
# FOR
# BANKS AND FINANCIAL INSTITUTIONS ON ITEMS TO BE INCLUDED IN FINANCIAL REVIEW FOR PUBLICATION

Banks should provide the following minimum information:

1) **Chairman's statement**
   - Overall business environment
   - Summary of the bank financial performance
   - Inform briefly on new products introduced if any
   - Ability to meet NBC regulation, and actions taken
   - Steps taken to strengthen the bank position and performance
   - Board focus and commitment

2) **Board of Directors Chart**
   - How duties and responsibilities are divided within the bank
   - Reporting and management of work

3) **Report of the Board of Directors**
   - Directors' report
   - Principal activities during the year

4) **Policy and Practice Guidelines for Corporate Governance**
   - Selection of directors
   - Board of directors
     - Board composition
     - Board and Directors' profile
     - Board meetings
   - Internal control
   - Risks management
   - Code of ethics
   - Independency and transparency

5) **Business description**
   - Principal activities of the bank
   - Mission and vision
   - Bank philosophy
     - ✓ Customers
     - ✓ Employers
     - ✓ Environment, Social and Community
     - ✓ Shareholders

6) **Financial Highlights (key performance indicators)**
- Profitability
- Balance sheet summary
- Financial ratio
- Other items (dividends, capital management)

7) **Analysis of the results (key performance indicators)**
- Detail analysis of each item of the key performance

8) **Business Operation Target**
- Financial perspective
- Customer perspective
- Internal process perspective
- Human resource development
- Significant operation plan for the following year

9) **Financial risk management policies**
- Operational risk
- Credit risk
  - ✓ Non performing loans
  - ✓ Debt restructuring
  - ✓ Risk from concentration of loans (large exposures)
  - ✓ Risk from collateral impairment
- Market risk
  - ✓ Foreign currency exchange risk
  - ✓ Interest rate risk
  - ✓ Liquidity risk

10) **Directors' declaration on the financial statements**

11) **Independent Audit Report**

12) **Shareholding Information (Quantitative)**

13) **Financial statements including notes to the financial statements**

14) **Bank representation (branches and international correspondents)**
- Branches and international correspondent

15) **Significant changes during the year**

16) **Three year financial summary**
- Overview

**ឧបសម្ព័ន្ធទី១**

ប្រកាសលេខ ធ ៧-០៤-២០៤ ប្រក
ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៤

## របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំស្របតាមបទដ្ឋានគណនេយ្យកម្ពុជា (CAS) និងការណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ នៅក្នុងករណីដែលបទដ្ឋានគណនេយ្យកម្ពុជាមិនបានបញ្ជាក់អំពីប្រព្រឹត្តិកម្មគណនេយ្យ ឬតំរូវការបើកចំហពត៌មាន បទដ្ឋានរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ត្រូវបានប្រើជំនួស។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងរាល់ស្ថានភាព ដែលមានទំនាស់កើតឡើងរវាងការណែនាំរបស់ធនាគារជាតិនៃកម្ពុជា និង CAS ឬ IFRS ការណែនាំរបស់ធនាគារជាតិនៃកម្ពុជាត្រូវបានទទួលស្គាល់ជាផ្លូវការ។

### ១. តារាងតុល្យការ

១-១ ធនាគារត្រូវតែបង្ហាញនូវពត៌មានអប្បបរមានៅក្នុងតារាងតុល្យការ ឬ ក្នុងកំណត់សំគាល់នៃរបាយការណ៍ហិរញ្ញវត្ថុដូចខាងក្រោម :

**ទ្រព្យសកម្ម**

សាច់ប្រាក់

សមតុល្យជាមួយធនាគារកណ្តាល

សមតុល្យជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្សេងទៀត

ការដាក់ប្រាក់បញ្ញើ និងការផ្តល់ឥណទានទៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត

មូលប័ត្រ និងប័ណ្ណរតនាគាររបស់រាជរដ្ឋាភិបាល

មូលប័ត្រ និងប័ណ្ណរតនាគាររបស់រដ្ឋាភិបាលផ្សេងទៀត

ផលប័ត្រពាណិជ្ជកម្ម

ប័ណ្ណត្រូវទទួល

ការអោយខ្ចីចងការ និងបុរេប្រទានចំពោះអតិថិជន (កំណត់សំគាល់ ១.៥)

សំវិធានធនលើបំណុលអាក្រក់ និងសង្ស័យ

- សំវិធានធនជាក់លាក់
- សំវិធានធនទូទៅ

ការវិនិយោគលើមូលប័ត្រដែលមានជាកម្មសិទ្ធិ (ធ្វើការវិភាគថាតើជាមូលនិធិ ឬបំណុល)

ទ្រព្យសកម្មផ្សេងទៀត (ផ្តល់ពត៌មានលំអិតនៃខ្ទង់សំខាន់ៗ)

ប្រាក់ជំពាក់របស់ក្រុមហ៊ុនភាគទុនិក

ប្រាក់ជំពាក់របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ធ្វើការវិភាគថាតើជាមូលធនឬបំណុល)

ការវិនិយោគនៅក្នុងក្រុមហ៊ុនដែលជាសម្ព័ន្ធញាតិ (ធ្វើការវិភាគថាតើជាមូលប័ត្របំណុល ឬ មូលប័ត្រភាគហ៊ុន)

អចលនទ្រព្យ (កំណត់សំគាល់ ១.៤)

ទ្រព្យសម្បត្តិដែលរឹបអូសពីកូនបំណុល (កំណត់សំគាល់ ១.៤)

**ទ្រព្យអកម្ម**

ប្រាក់បញ្ញើ និងសមតុល្យរបស់ធនាគារផ្សេងៗ

ប្រាក់បញ្ញើរបស់អតិថិជនមិនមែនជាធនាគារ

សវិធានធនលើពន្ធ

ប័ណ្ណ និងរូបិយណត្តិត្រូវសង

ប្រាក់កំចីផ្សេងៗ

ទ្រព្យអកម្មផ្សេងៗ (ដើម្បីផ្តល់នូវការបំបែកនៃខ្ទង់សំខាន់ៗ)

ភាគលាភដែលត្រូវសង

ប្រាក់ជំពាក់ក្រុមហ៊ុនភាគទុនិក

ប្រាក់ជំពាក់ក្រុមហ៊ុនបុត្រសម្ព័ន្ធ

មូលប័ត្របំណុលដែលបានចេញផ្សាយ (កំណត់សំគាល់១.៣)

ប្រាក់ជំពាក់ភាគទុនិក

ដើមទុននិងប្រាក់បំរុង

ដើមទុនរួមចំណែក (សាខាបរទេស)

ភាគហ៊ុន (ដែលបានចុះបញ្ជី ចេញផ្សាយ និងទទួលស្គាល់)

ប្រាក់ខ្ចីបំពេញដើមទុន

ប្រាក់បំរុង (ធ្វើការវិភាគទៅតាមប្រភេទនីមួយៗនៃទុនបំរុង ដោយរួមបញ្ចូលទាំងការវាយតំលៃឡើងវិញទុនបំរុង (កំណត់សំគាល់១.២)

ប្រាក់ចំណេញរក្សាទុក / ការបង្ខូតខាត

១.២ ធនាគារត្រូវតែបង្ហាញចំនួននៃប្រាក់បំរុងទៅតាមប្រភេទនីមួយៗនៅដើមឆ្នាំនិងចុងឆ្នាំនៃការិយបរិច្ឆេទគណនេយ្យ ព្រមទាំងចំនួននៃការផ្ទេរទៅ ឬផ្ទេរមកពីប្រភេទនីមួយៗនៃទុនបំរុងនៅក្នុងកំឡុងឆ្នាំ។

| | ភាគហ៊ុនធម្មតា | ទុនបំរុងធនាគារទូទៅ | ទុនបំរុង | ការវាយតំលៃឡើងវិញនៃមូលប័ត្រភាគហ៊ុនរយៈពេលវែងដែលអាចលក់បាន | ប្រាក់ចំណេញរក្សាទុក |
|---|---|---|---|---|---|
| សមតុល្យដើមគ្រា | | | | | |
| + ការផ្ទេរចូលទុនបំរុង | | | | | |
| - ការដកចេញពីទុនបំរុង | | | | | |
| សមតុល្យចុងគ្រា | | | | | |

១.៣ ចំពោះមូលប័ត្របំណុលចេញផ្សាយដោយធនាគារដែលមានឥណប្រតិទានដំបូងច្រើនជាង១ឆ្នាំ ធនាគារត្រូវបង្ហាញអត្រាការប្រាក់ (ចំពោះមូលប័ត្រដែលអត្រាការប្រាក់ថេរ) ឬវិធីសាស្ត្រកំណត់អត្រាការប្រាក់ (ចំពោះមូលប័ត្រដែលមានអត្រាការប្រាក់អណ្តែត) និងកាលបរិច្ឆេទទូទាត់សង។

១.៤ ធនាគារត្រូវបង្ហាញពីតំលៃទីផ្សារនៃការវិនិយោគ ទ្រព្យសម្បត្តិរបស់ធនាគារ និងទ្រព្យសម្បត្តិដែលរឹបអូសពីកូនបំណុល។ (ស្របនឹងតំរូវការនៃប្រកាសលេខ ធ៧.០១-១៨៦ ប្រក ស្តីពីអចលនទ្រព្យរបស់ធនាគារ)

១.៥ អោយខ្ចីចងការ និងបុរេប្រទានទៅអតិថិជន ៖

| | សមតុល្យដើមគ្រា | សមតុល្យចុងគ្រា |
|---|---|---|
| ឥណទានទៅរដ្ឋាភិបាល | | |
| - រាជរដ្ឋាភិបាលកម្ពុជា | | |
| - ផ្សេងៗ | | |
| ឥណទានពាណិជ្ជកម្ម | | |
| - ឥណទានវិបារូបន៍ | | |
| - ឥណទានរយៈកាលខ្លី | | |
| - ឥណទានរយៈកាលវែង | | |
| - ឥណទានភតិសន្យា | | |
| - ឥណទានសម្ព័ន្ធញាតិ | | |
| - ឥណទានពាណិជ្ជកម្មផ្សេងទៀត | | |
| ឥណទានចំពោះអ្នកប្រើប្រាស់ | | |
| - អចលនទ្រព្យ | | |
| - ឥណទានវិបារូបន៍ | | |
| - ឥណទានចំពោះអ្នកប្រើប្រាស់ | | |
| - ផ្សេងទៀត | | |
| ឥណទានសរុប | | |

ចំពោះខ្លឹមសារនៃ " ឥណទានសម្ព័ន្ធញាតិ " ដែលមានចែងនៅក្នុងមាត្រាទី ៤៩ និង ៥០ ក្នុងជំពូក១៦ នៃច្បាប់ស្តីពី **គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។**

**១.៦** ធនាគារត្រូវបង្ហាញចំនួនសរុបដុលនៃឥណទានដំណើរការ និងឥណទានមិនដំណើរការ ( បំណុលដែលមានការធានា និងបំណុលមិនមានការធានា ) ដែលបានកំណត់ជា បំណុលស្តង់ដារ បំណុលក្រោមស្តង់ដារ បំណុលសង្ស័យ និងបំណុលបាត់បង់ ស្របតាមប្រកាសលេខ ធ៧.០០-៥១ ស្តីពីចំណាត់ថ្នាក់ និងសវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យ និងប្រកាសលេខ ធ៧.០២-១៤៥ ស្តីពីវិសោធនកម្មលើប្រកាសលេខ ធ៧.០០-៥១ មាន

| | សមតុល្យចុងគ្រា | សមតុល្យដើមគ្រា |
|---|---|---|
| បំណុលស្តង់ដារ | | |
| - មានការធានា | | |
| - មិនមានការធានា | | |
| បំណុលក្រោមស្តង់ដារ | | |
| - មានការធានា | | |
| - មិនមានការធានា | | |
| បំណុលសង្ស័យ | | |
| - មានការធានា | | |
| - មិនមានការធានា | | |
| បំណុលបាត់បង់ | | |
| - មានការធានា | | |
| - មិនមានការធានា | | |

**១.៧** ធនាគារត្រូវផ្តល់នូវតារាងដែលបង្ហាញពីបំរែបំរួលសមតុល្យនៃសវិធានធននៅដើមគ្រា ការដកចេញ ឬបូកបញ្ចូលក្នុងគណនីចំណេញ-ខាតនៅក្នុងឆ្នាំ ចំនួនទឹកប្រាក់ប្រើប្រាស់សំរាប់លុបចោលបំណុលអាក្រក់ប្រចាំឆ្នាំនិងសមតុល្យចុងគ្រា ដែលត្រូវអនុវត្តតាម :

- សវិធានធនជាក់លាក់សំរាប់បំណុលបាត់បង់
- សវិធានធនជាក់លាក់សំរាប់ការថយចុះតំលៃនៃការវិនិយោគ និងទ្រព្យសកម្មដទៃទៀត
- សវិធានធនទូទៅ សំរាប់បំណុលបាត់បង់ដែលអាចកើតឡើង និងហានិភ័យធនាគារផ្សេងៗទៀត

តារាងស្រដៀងគ្នាដែលបង្ហាញពីបំរែបំរួលនៃការប្រាក់ព្យួរទុក ធនាគារត្រូវផ្តល់អោយផងដែរ ។

**១.៨** ទ្រព្យសកម្មដែលបានសន្យាជាវត្ថុធានាជាមួយភាគីទីបី រួមទាំងចំនួនសរុបនៃបំណុលដែលមានការធានាត្រូវធ្វើការបង្ហាញផងដែរ ។

## ២. របាយការណ៍ចំណេញ-ខាត

ធនាគារត្រូវតែបង្ហាញនូវពត៌មានអប្បបរមានៅក្នុងរបាយការណ៍ចំណេញ-ខាត ឬក្នុងកំណត់សំគាល់របាយ-ការណ៍ហិរញ្ញវត្ថុ ដូចខាងក្រោម :

- ចំណូលពីការប្រាក់
- ចំណាយការប្រាក់
- ចំណូលពីការប្រាក់សុទ្ធ
- ចំណូលពីប្រតិបត្តិការផ្សេងៗ
    - ចំណេញ (ខាត) ពីសកម្មភាពជួញដូរ (ធ្វើការវិភាគលើចំណូលដែលបានមកពីការជួញដូររូបិយប័ណ្ណ មូលប័ត្រ និងឧបករណ៍ហិរញ្ញវត្ថុដោយឡែកពីគ្នា) ។
    - ថ្លៃឈ្នួល និងកំរៃជើសារ
    - ភាគលាភ (ធ្វើការវិភាគលើចំណូលភាគលាភដែលបានមកពីបុគ្គលសម្ព័ន្ធមកពីក្រុមហ៊ុនដែលជាសម្ព័ន្ធញាតិនិងមកពីការវិនិយោគផ្សេងទៀតដោយឡែកពីគ្នា) ។
    - ថ្លៃជួល
    - ចំណេញ (ខាត) ពីការលក់មូលប័ត្រវិនិយោគ
    - ចំណូលផ្សេងៗ

ចំណាយលើប្រតិបត្តិការផ្សេងៗ

- ការចំណាយលើបុគ្គលិក (រួមបញ្ចូលទាំងប្រាក់លើកទឹកចិត្ត)
- ការចំណាយលើអគ្គនាយក និងអត្ថប្រយោជន៍បន្ថែម
- ប្រាក់កំរៃរបស់សវនករ
- រំលោះលើទ្រព្យសកម្មរូបិយ
- រំលោះលើទ្រព្យសកម្មអរូបិយ
- ការថែរក្សា និងការជួលនៃអចលនទ្រព្យ
- ការចំណាយលើអាគារ (ការថែរក្សានិងការធានារ៉ាប់រង)
- ចំណាយផ្សេងៗ
- ចំណាយលើសន្តិសុខ (ធានារ៉ាប់រងលើការដឹកជញ្ជូនសាច់ប្រាក់ ការថែរក្សាអាគារ និងអតិថិជន) ។

ប្រាក់ចំណេញពីប្រតិបត្តិការ

សំវិធានធនសំរាប់ឥណទានបាត់បង់ដែលអាចកើតមាននិងការថយចុះតំលៃនៃទ្រព្យសកម្មដទៃទៀត

- សំវិធានធនជាក់លាក់សំរាប់បំណុលបាត់បង់
- សំវិធានធនជាក់លាក់សំរាប់ការថយចុះតំលៃនៃការវិនិយោគ និងទ្រព្យសកម្មដទៃទៀត
- សំវិធានធនទូទៅ រួមបញ្ចូលទាំងសំវិធានធនសំរាប់បំណុលបាត់បង់ដែលអាចកើតមាន និងហានិភ័យធនាគារដទៃទៀត
- ការប្រមូលបានមកវិញនូវសំវិធានធន និងចំណាយដែលបានលុបចោលពីគ្រាមុន
- ចំនួនដែលបានលុបចោល

ការបែងចែកប្រាក់ចំណេញ (ខាត) នៃក្រុមហ៊ុនសម្ព័ន្ធញាតិ

ចំណាយបង់ពន្ធ

ជំពូកវិសាមញ្ញ

ប្រាក់ចំណេញមិនសមស្របផ្ទេរមកពីឆ្នាំមុន

ភាគលាភ

- ភាគលាភបណ្តោះអាសន្ន
- ភាគលាភចុងក្រោយដែលបានស្នើ

ផ្ទេរទៅទុនបំរុងទូទៅ

ប្រាក់ចំណេញមិនសមស្របផ្ទេរទៅគ្រាខាងមុខ

## ៣. របាយការណ៍លំហូរសាច់ប្រាក់

ធនាគារត្រូវតែរៀបចំរបាយការណ៍លំហូរសាច់ប្រាក់។

## ៤. ជំពូកក្រៅតារាងតុល្យការ

ធនាគារត្រូវតែបង្ហាញពីការបែងចែកខ្ទង់ក្រៅតារាងតុល្យការជាបំផ្លែកដូចតទៅ :

- កិច្ចសន្យាយថាភាព. ត្រូវបង្ហាញចំនួនទឹកប្រាក់នៃកិច្ចសន្យាសំរាប់ធាតុនីមួយៗខាងក្រោម ឬធាតុណាដែលមានចំណាត់ថ្នាក់ប្រហាក់ប្រហែលនឹងធាតុដូចខាងក្រោម :
  - ជំនួសឥណទានផ្ទាល់
  - យថាភាពពាក់ព័ន្ធនឹងប្រតិបត្តិការ
  - យថាភាពពាក់ព័ន្ធនឹងពាណិជ្ជកម្ម
  - កិច្ចសន្យាយថាភាពផ្សេងៗ

- ការសន្យាត្រូវបង្ហាញពីចំនួនទឹកប្រាក់នៃខ្ទង់នីមួយៗដែលបានសន្យាដូចខាងក្រោម :
  - ក៏រិតឥណទានមិនបានដក និងការសន្យាពន្យារពេលឥណទានផ្សេងៗ
  - កិច្ចសន្យាផ្តល់ឥណទានដែលមិនទាន់បានដកប្រើ និងការបន្តលើកិច្ចសន្យាផ្តល់ឥណទាន
  - ការទិញ ឬលក់ទ្រព្យសកម្ម និងការដាក់ប្រាក់បញ្ញើនៅពេលអនាគត
  - ការសន្យាផ្សេងៗ
- ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទនីដែលមានជារូបិយប័ណ្ណបរទេស អត្រាការប្រាក់ និងដើមទុន ដុំមាសឬប្រាក់ និងទំនិញប្រើប្រាស់ផ្សេងៗ រួមទាំងកិច្ចសន្យាផ្សេងៗដែលពាក់ព័ន្ធ។ កិច្ចសន្យាទាំងនោះមានការទិញលក់រូបិយប័ណ្ណនិងផលប័ត្រនាពេលអនាគត ការដោះដូររូបិយប័ណ្ណ និងអត្រាការប្រាក់ ការយល់ព្រមកំណត់អត្រានាពេលអនាគត សិទ្ធិទិញឬលក់ដែលកំណត់តំលៃជាក់លាក់សំរាប់ពេលខាងមុខ។ ក្នុងករណីចាំបាច់ ធនាគារត្រូវបង្ហាញនូវចំនួនទឹកប្រាក់នៃកិច្ចសន្យា តំលៃទីផ្សារដុលវិជ្ជមានឬអវិជ្ជមាន និង ឥទ្ធិពលនៃកិច្ចព្រមព្រៀងសរុបដែលអាចអនុវត្តបានតាមផ្លូវច្បាប់ចំពោះខ្ទង់នីមួយៗ។ ក្នុងករណីចាំបាច់ ពត៌មានដូចគ្នានេះត្រូវផ្តល់អោយសំរាប់ទំនិញប្រើប្រាស់និងឥណទាននិស្សន្ទនី។ ត្រូវរៀបរាប់អោយដាច់នៃប្រតិបត្តិការទៅលើឧបករណ៍និស្សន្ទនី រវាងប្រតិបត្តិការបញ្ចៀសហានិភ័យនិងប្រតិបត្តិការពាណិជ្ជកម្ម។

## ៥. គោលការណ៍គណនេយ្យ

ធនាគារត្រូវតែបង្ហាញឱ្យឃើញនូវគោលការណ៍គណនេយ្យសំខាន់ៗ ដែលបានអនុម័តក្នុងការរៀបចំនិងការបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុ។ ចំនុចខាងក្រោមត្រូវបង្ហាញក្នុងគោលការណ៍គណនេយ្យ ប៉ុន្តែមិនកំណត់ត្រឹមតែចំនុចទាំងនេះទេ :

- មូលដ្ឋាននៃការទទួលស្គាល់នូវប្រភពប្រាក់ចំណូលសំខាន់ៗ
- ការផ្លាស់ប្តូរវិធីសាស្ត្រគណនេយ្យក្នុងកំឡុងនៃឆ្នាំ ដែលក្នុងករណីនេះគណនីហិរញ្ញវត្ថុនៃឆ្នាំមុនត្រូវបានបង្ហាញជាមួយវិធីសាស្ត្រថ្មី
- មូលដ្ឋានសំរាប់ធ្វើសំវិធានធនជាក់លាក់ទៅលើឥណទានបាត់បង់ និងធ្វើសំវិធានធនទូទៅសំរាប់ហានិភ័យឥណទានឬសំរាប់ហានិភ័យធនាគារដទៃទៀត
- វិធីសាស្ត្រនៃការវាយតំលៃទៅលើមូលប័ត្រវិនិយោគ ការជួញដូរមូលប័ត្រ និងឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទនី
- ការធ្វើរំលោះទៅលើអចលនទ្រព្យ
- មូលដ្ឋាននៃការរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុ
- ការផ្ទេរតំលៃទ្រព្យសកម្ម និងទ្រព្យអកម្មរូបិយប័ណ្ណបរទេសមកជារូបិយប័ណ្ណក្នុងស្រុក ។

**៦_ការរាត់ចំណែកនៃពត៌មាន**

**៦-១** ធនាគារត្រូវវិភាគឥណទាន និងបុរេប្រទានទៅតាមជំពូកនៃវិស័យដូចខាងក្រោម (ការប្រមូលផ្តុំនូវការផ្តល់ទុនទៅតាមវិស័យ)

- កសិកម្ម
- ឧស្សាហកម្ម
- សំណង់ និងការស្ថាបនា
- ផ្ទះ (ទិញ)
- លក់ដុំ និងលក់រាយ
- នាំចេញ
- នាំចូល
- ដឹកជញ្ជូន និងគមនាគមន៍
- សេវាកម្ម
- វិជ្ជាជីវៈ និងការប្រើប្រាស់ជាឯកជន (លើកលែងការឱ្យខ្ចីសំរាប់ទិញផ្ទះ)
- ផ្សេងៗ

**៦-២** ធនាគារត្រូវផ្តល់នូវការវិភាគឥណប្រតិទានសំរាប់ការឱ្យខ្ចី (ទាំងធនាគារ និងមិនមែនធនាគារ) និងការដាក់ប្រាក់បញ្ញើ (ធនាគារ និងមិនមែនធនាគារ) ទៅតាមប្រភេទនៃកាលវសាន្ត ដូចខាងក្រោម :

- កាលវសាន្តរយះពេល ១ឆ្នាំ
- ច្រើនជាង ១ឆ្នាំ តែតិចជាង ៣ឆ្នាំ
- ច្រើនជាង ៣ឆ្នាំ តែតិចជាង ៥ឆ្នាំ
- ច្រើនជាង ៥ឆ្នាំ

ការវិភាគទៅតាមប្រភេទនៃដល់ឥណប្រតិទាននីមួយៗ ត្រូវផ្អែកលើពេលវេលាដែលនៅសល់រហូតដល់កាលវសាន្តតាមកិច្ចសន្យានៅក្នុងកាលបរិច្ឆេទតារាងតុល្យការ ។

**៧_ការត្រួតពិនិត្យ**

ធនាគារត្រូវបង្ហាញពត៌មានដូចខាងក្រោមសំរាប់គោលបំណងនៃការត្រួតពិនិត្យ ហើយពត៌មានទាំងនោះ មិនចាំបាច់បោះផ្សាយសំរាប់សាធារណជននោះទេ ។

**៧-១** បទបញ្ញត្តិប្រុងប្រយ័ត្ន

- ប្រកាសស្តីពីអនុបាតសាច់ប្រាក់ងាយស្រួលលេខ ធ៧-០០-៣៨ និងប្រកាសស្តីពីវិនិយោគកម្មលេខ ធ៧០២-១៨៧ ប្រក.
  - ក- ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល
  - ខ- ចំណាត់ថ្នាក់សាច់ប្រាក់ងាយស្រួល
- ប្រកាសស្តីពីមូលនិធិផ្ទាល់សុទ្ធ លេខ ធ៧-០០-៤៧ ប្រក

- ប្រកាសស្តីពីបាតសាធនភាព លេខ ធ៧-០០-៤៦ ប្រក
- ប្រកាសស្តីពីសវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យ លេខ ធ៧-០០-៥១ ( ឧបសម្ព័ន្ធ ២)

**៧-២** ពត៌មានបន្ថែម ( ឧបសម្ព័ន្ធ ៣)

**៧-៣** សូចនាករហិរញ្ញវត្ថុសំខាន់ៗ

- ដើមទុន
- ទ្រព្យសកម្ម
- ប្រាក់ចំណេញ
- សាច់ប្រាក់ងាយស្រួល

**៧-៤** របាយការណ៍របស់អ្នកគ្រប់គ្រង

អនុសាសន៍របស់សួងការគណនេយ្យ គត់សំគាល់ពីចំណុចខ្សោយដែលបានរកឃើញនៅក្នុងពេលធ្វើសវនកម្ម ប៉ុន្តែមិនកំណត់តែចំនុចដូចមានចែងខាងក្រោមទេ :

១- រាល់កិច្ចសន្យា និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខារវាងធនាគារ និងម្ចាស់ភាគហ៊ុន នាយកគ្រប់គ្រង និងភាគីពាក់ព័ន្ធដទៃទៀត)

២- ការផ្លាស់ប្តូរអ្នកគ្រប់គ្រង (បុគ្គលិកជាន់ខ្ពស់ ភាពញឹកញាប់ មូលហេតុ និងជំលោះផលប្រយោជន៍ជាសក្តានុពល ការតែងតាំងក្រុមប្រឹក្សាភិបាល)

៣- ការឧទ្ទេសនាមផលិតផលថ្មី (ការលក់មូលប័ត្រទេសចរណ៍ និងកិច្ចសន្យាដោះដូរ)

៤- កិច្ចសន្យាថ្មី ( កតិសន្យាថ្មី កិច្ចព្រមព្រៀងរវាងភ្នាក់ងារនិងធនាគារ)

៥- ការបើកសាខាថ្មី (មូលហេតុ គោលបំណង និងការចាត់តាំងបុគ្គលិក)

៦- គុណភាពនៃសំពាធឥណទាន (ការប្រមូលផ្តុំឥណទាន តំបន់ ឧស្សាហកម្ម និងបុគ្គល)

៧- ការវិនិយោគក្នុងឆ្នាំ ( មូលហេតុ ការអនុម័ត កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល)

៨- ភាពគ្រប់គ្រាននៃសវិធានធន

៩- ប្រតិបត្តិការកុំព្យូទ័រ ( សុវត្ថិភាព ការរក្សាទុក បុគ្គលិក ប្រសិទ្ធិភាព និង ហានិភ័យ)

១០- ផែនការប្រមូលការខូចខាតមកវិញក្នុងពេលអាសន្ន

១១- គោលនយោបាយសំរាប់ការគ្រប់គ្រងការប្រឈមមុខនឹងហានិភ័យរូបិយវត្ថុ ( ពត៌មានបែបបរិមាណ)

១២- ចំនុចខ្សោយដទៃទៀតដែលអាចប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ

**ឧបសម្ព័ន្ធទី២**

ប្រកាសលេខ ធ ៧-០៤-២០៤ ប្រក

ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៤

## សំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យ

ការធ្វើសំវិធានធនជាក់លាក់ត្រូវរៀបចំឡើងដោយអនុលោមទៅតាមប្រកាសលេខ ធ៧-០០-៥១ ស្តីពីចំណាត់ថ្នាក់ និងការធ្វើសំវិធានធនសំរាប់បំណុលអាក្រក់ និងបំណុលសង្ស័យ ដោយរួមបញ្ចូលការប្រាក់ដែលព្យួរទុក និងប្រកាស លេខ ធ៧-០២-១៤៥ ប្រក ស្តីពីវិសោធនកម្មលើប្រកាសលេខ ធ៧-០០-៥១

| អតិថិជន | ទឹកប្រាក់ជាប្រាក់ដុល្លា | ចំណាត់ថ្នាក់តាម NBC | ការប្រាក់ព្យួរទុក | តំលៃបាំន់ស្មានរបស់វត្ថុបញ្ចាំ | សំវិធានធនតាមតំរូវការរបស់ NBC (១) | សំវិធានធនដែលបានកត់ត្រាដោយធនាគារ(២) | ចំនួនខុសគ្នានៅក្នុងការធ្វើសំវិធានធន ៣=(១)-(២) |
|---|---|---|---|---|---|---|---|
| | | ក្រោមស្តង់ដា | | | | | |
| | | អាក្រក់ | | | | | |
| | | បាត់បង់ | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

**ឧបសម្ព័ន្ធទី៣**

ប្រកាសលេខ ធ ៧-០៤-២០៤ ប្រក

ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៤

**ឈ្មោះធនាគារ ..............................**

(I). ធាតុនីមួយៗនៃតារាងតុល្យការ

(ក). (១) សរុបឥណទានទៅតាមចំណាត់ថ្នាក់ ដែលបានផ្តល់ទៅអោយអតិថិជន . ចំនួនទឹកប្រាក់

- ក្រោមស្តង់ដារ
- សង្ស័យ
- បាត់បង់

ដក : ទឹកប្រាក់ជាំន់ស្មានដែលអាចទារមកវិញបាន

ទឹកប្រាក់ជាំន់ស្មានដែលមិនអាចទារមកវិញបាន

(២) សំវិធានធនជាក់លាក់ សំរាប់ឥណទានបាត់បង់និងសង្ស័យ

- អោយខ្ចីចងការ និងបុរេប្រទាន
- បណ្ណើឥណទេយ្យ

(៣) សំវិធានធនទូទៅសំរាប់ឥណទាន

(ខ). មូលប័ត្រវិនិយោគរយៈពេលខ្លីនិងរយៈពេលវែង

| ការពិពណ៌នា | ថ្លៃដើម | តំលៃចារឹកសន្លឹកប័ណ្ណ | បុព្វលាភដែលមិនទាន់រំលស់ក្នុងដំណាក់កាល | អប្បហារមិនទាន់រំលស់ក្នុងដំណាក់កាល | ការធ្លាក់ចុះនៃតំលៃ | | តំលៃក្នុងបញ្ជី | តំលៃទីផ្សារ (ចំណាយការប្រាក់ក្នុងករណីមូលប័ត្របំណុល) |
|---|---|---|---|---|---|---|---|---|
| | | | | | សំវិធានធនដែលបានធ្វើ | ចំនួនដែលបានលុបចោល | | |
| (១) ប័ណ្ណរតនាគាររបស់រដ្ឋាភិបាល | | | | | | | | |
| (២) ប័ណ្ណរតនាគាររបស់រដ្ឋាភិបាលផ្សេងទៀត | | | | | | | | |
| (៣) ការវិនិយោគលើក្រុមហ៊ុនដែលជាសាខា | | | | | | | | |
| (៤) ការវិនិយោគលើក្រុមហ៊ុនដែលពាក់ព័ន្ធ | | | | | | | | |
| (៥) ការវិនិយោគដទៃទៀត | | | | | | | | |
| - ការវិនិយោគជាដើមទុន | | | | | | | | |
| - ក្រដាសដទៃទៀត | | | | | | | | |

* មិនរួមបញ្ចូលប័ណ្ណអប្បហារ

(គ). អាគារធនាគារ និងទ្រព្យសម្បត្តិដទៃទៀតដែលមិនអាចធ្វើចលនាបាន ចំនួន

(១) ថ្លៃដើមរបស់ទ្រព្យសម្បត្តិ ______

(២) ចំនួនដែលបានលុបចោល ______

(៤) សវិធានធនសំរាប់រំលោះ ឬការបាត់បង់ ______

(៥) តំលៃទីផ្សារ ឬតំលៃទីផ្សារដែលប៉ាន់ស្មាន (បង្ហាញកាលបរិច្ឆេទ និងការវាយតំលៃចុងក្រោយបំផុតរបស់អ្នកវាយតំលៃដែលមានវិជ្ជាជីវៈ)។ បង្ហាញបញ្ជីទ្រព្យសម្បត្តិអាស័យដ្ឋាន និងសេចក្តីលំអិតដទៃទៀត * ______

(ឃ). ប្រាក់បំរុងដើមទុន

(១) ប្រាក់បំរុងបុព្វលាភរបស់សន្លឹកហ៊ុន ______

(២) ប្រាក់បំរុងវាយតំលៃ ______

(៣) ប្រាក់បំរុងដើមទុនដទៃទៀត ______

(ង). ប្រាក់បំរុងចំណូល **

(១) ប្រាក់បំរុងកាតព្វកិច្ច ______

(២) ប្រាក់បំរុងចំណូលដទៃទៀត ______

(៣) ចំណេញ ឬខាតដែលមិនសមស្រប ______

(ច). សវិធានធនដទៃទៀត និងការបំរុងទុកសំរាប់ការបាត់បង់ ឬយោងទៅការផ្តល់សេចក្តីលំអិត នៃការធ្វើសវិធានធន និងប្រាក់បំរុងដទៃទៀត " ដោយបញ្ជាក់ពីគោលបំណងនៃការបំរុងទុកនោះ " ដែលបានបែងចែកទៅតាមខ្ទង់ (បំណុលដទៃទៀតដែលបានរួមបញ្ចូលសវិធានធន និងការបំរុងទុកដទៃទៀត) នៅក្នុងតារាងតុល្យការ។ ______

(ឆ). ផ្តល់ព័ត៌មានលំអិតអំពីខ្ទង់ដែលបានបញ្ចូលនៅក្នុង " គណនីដទៃទៀត " ______

(ជ). (១) ប្រាក់បញ្ញើសរុបរបស់អតិថិជនដែលមិនមែនធនាគារ ______

(២) ប្រាក់បញ្ញើនិងសមតុល្យរបស់ធនាគារ និងភ្នាក់ងារ ______

(ឈ). ប្រសិនបើអាចធ្វើបាន គួរតែភ្ជាប់មកជាមួយនូវខ្ទង់ដូចខាងក្រោម

---

* លុបចោលនៅពេលចាំបាច់

** - ប្រាក់បំរុងកាតព្វកិច្ចដែលបានកំណត់នៅក្នុងប្រកាសលេខ ៧-៩៧-០២-ធជ.

- ប្រាក់បំរុងចំណូលដទៃទៀតគឺចំនួនដែលលើសពីប្រាក់បំរុងកាតព្វកិច្ច

(១) វាយឈ្មោះប្រភេទឥណទានប្រើប្រាស់ ដោយក្រុមហ៊ុនដែលធនាគារកាន់កាប់ភាគហ៊ុន ដោយផ្ទាល់ឬដោយប្រយោល ។

(២) វាយឈ្មោះឥណទាន និងប្រភេទឥណទានដទៃទៀតដែលបានផ្តល់ទៅអោយសម្ព័ន្ធញាតិ ដូច មានចែងក្នុងមាត្រា ៤៨-៥០ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

(៣) វាយឈ្មោះទ្រព្យសម្បត្តិរបស់ធនាគារ ដែលបានដាក់បញ្ចាំឬផ្ញើទៅធនាគារ និងគ្រឹះស្ថាន ហិរញ្ញវត្ថុដទៃទៀត ។ល។ ដូចជាវត្ថុធានាសំរាប់មូលនិធិដែលបានផ្តល់អោយធនាគារឬ ភាគីណាមួយ ដោយប្រើមធ្យោបាយជាប្រាក់បញ្ញើ ឥណទាន បុរេប្រទាន ឬមធ្យោបាយ ដទៃទៀត។

([illegible]). របាយការណ៍ចំណេញ-ខាត

(១) របាយការណ៍ចំណេញ ខាតដែលបានធ្វើសវនកម្មរួចមួយច្បាប់ ដែលបង្ហាញសេចក្តីលំអិត អំពីចំណូល និងចំណាយរបស់ធនាគារ និង

(២) ភ្ជាប់មកជាមួយនូវរបាយការណ៍ចំណេញ ខាត មួយច្បាប់

-------------------------------------

នាយកប្រតិបត្តិ

-------------------------------------

នាយកគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ

យើងសូមអះអាងថា ព័ត៌មានហិរញ្ញវត្ថុដែលបានបញ្ជាក់ខាងលើអនុលោមទៅតាមបញ្ជី និង កំណត់ត្រាហិរញ្ញវត្ថុរបស់ធនាគារ ដែលបានរៀបចំឡើងផ្អែកលើមូលដ្ឋានសវនកម្មរបស់ធនាគារ។

-----------------------------

ក្រុមការគណនេយ្យឯករាជ្យ

**ឧបសម្ព័ន្ធទី៤**

ប្រកាសលេខ ធ ៧-០៤-២០៤ ប្រក

ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៤

## កំណត់សំគាល់

២ ដើមទុនថ្នាក់ ១ = ដើមទុនបានបង់ជំរះ (ភាគហ៊ុនធម្មតា) + ទុនបំរុង

៣.៤ និង៦ ទ្រព្យសម្បត្តិដែលបានថ្លឹងហានិភ័យរួច សំដៅលើភាគយករបស់អនុបាតសាធនភាព។ សំរាប់ពត៌មានលំអិត សូមមើលប្រកាសស្តីពីអនុបាតសាធនភាពរបស់ធនាគារ

៤ ដើមទុនថ្នាក់ ១ + ថ្នាក់២ = ដើមទុនបានបង់ជំរះ (ភាគហ៊ុនធម្មតា) + ទុនបំរុង + ទុនបំរុងទូទៅ + បំណុលបំពេញដើមទុន + ដើមទុនកូនកាត់ (ភាគហ៊ុនអតិភាព)

៩ ភាគលាភ សំដៅលើភាគលាភដែលបានបង់ក្នុងឆ្នាំ

១១ ទុនបំរុងសំរាប់ហានិភ័យធនាគារសំដៅលើគណនីលេខ ៤០៥០០០ នៅក្នុងប្លង់គណនី

១៤.១៦ ទ្រព្យសម្បត្តិដែលបានចាត់ថ្នាក់សំដៅលើឥណទានមិនដំណើរការ និងទ្រព្យសម្បត្តិទាំងឡាយណាដែលចាំបាច់ត្រូវធ្វើសំវិធានធន

១៨ សំរាប់និយមន័យនៃពាក្យ "ហានិភ័យធំៗ" សូមយោងទៅប្រកាសលេខ ធ៧-០០-៥២ ស្តីពីការត្រួតពិនិត្យលើហានិភ័យធំៗរបស់ធនាគារ។

២៤ សំវិធានធន = សំវិធានធនសំរាប់ការខាតបង់ឥណទាននិងភតិសន្យា (គណនីលេខ ១៧០០០០) + សំវិធានធនសំរាប់ការខាតបង់លើការវិនិយោគនិងមូលប័ត្រ (គណនីលេខ ២១៤០០០)។

៣១ សំវិធានធនកំណត់ដោយគណនីលេខ ៦៦១០០០ រួមមាន សំវិធានធនលើបំណុលអាក្រក់និងបំណុលសង្ស័យលើប្រាក់ដើមនិងបង្គរការប្រាក់ សំវិធានធនសំរាប់ការខាតបង់លើខ្ទង់ក្រៅតារាងតុល្យការ សំវិធានធនលើការខាតបង់ប្រាក់ដើមរបស់មូលប័ត្រ និងសំវិធានធនទូទៅ។

៣៤ ពន្ធ = ពន្ធប៉ាតង់ (៦៥៧១០០) + ពន្ធលើដីដែលមិនបានប្រើប្រាស់ (៦៥៧៤០០) + ពន្ធលើមធ្យោបាយដឹកជញ្ជូន (៦៥៨០០០) + ពន្ធលើប្រាក់ចំណេញ (៦៥៩១០០)។

៣៩ ទ្រព្យសម្បត្តិងាយក្លាយជាសាច់ប្រាក់ សូមយោងទៅខ្ទង់គណនាពន្ធដែលបានកំនត់នៅក្នុងប្រកាសលេខ ធ៧០០-៣៨ ស្តីអំពីអនុបាតសាច់ប្រាក់ងាយស្រួល។

៤២ Quick Assets = សាច់ប្រាក់ + មាស + ប្រាក់បញ្ញើនៅធនាគារជាតិ (មិនរាប់បញ្ចូលប្រាក់ធានាលើដើមទុន និងប្រាក់បំរុងកាតព្វកិច្ច) + ប្រាក់បញ្ញើនៅធនាគារដទៃទៀត

Appendix 4 attached to
Prakas No. B7-04-204 Prokor
date December 29, 2004

# FINANCIAL SOUNDNESS INDICATORS

## *CAPITAL*

1- Equity to Total Asset (A/B)
- A- Equity
- B- Total assets

2- Capital Tier I to Total Asset (A/B)
- A- Capital tier I
- B- Total assets

3- Capital Tier I to Risk weighted Asset (A/B)
- A- Capital tier I
- B- Risk weighted assets

4- Capital Tier 1+Tier 2 to Risk Weighted Asset (A/B)
- A- Capital tier 1+ tier 2
- B- Risk weighted assets

5- Net Worth to Total Assets (A/B)
- A- Net worth
- B- Total assets

6- Solvency Ratio (A/B)
- A- Net worth
- B- Risk weighted assets

7- Debt to Total Asset (A/B)
- A- Total liabilities
- B- Total assets

8- Debt to Equity (A/B)
- A- Total liabilities
- B- Equity

9- Dividend to Net Profit (A/B)
- A- Dividend
- B- Net profit

## *ASSET QUALITY*

10- Banking Reserve to Total Loans (A/B)
- A- Banking reserves
- B- Total loans (gross

11- Banking Reserves to Total Assets (A/B)
- A- Banking reserves
- B- Total assets

12- NPL to Total Loan (A/B)
- A- NPL
- B- Total loans (gross

13- NPL to Tatal Asset (A/B)
- A- NPL
- B- Total assets

14- Classfied Asset to Total Loan (A/B)
- A- Classified assets
- B- Total loans (gross)

15- Classified Asset to Tatal Asset (A/B)
- A- Classified assets
- B- Total assets

16- Classified Asset to Equity (A/B)
- A- Classified assets
- B- Equity

17- Loan to Related Parties to Total Loan (A/B)
- A- Loan to related parties
- B- Total loans (gross)

18- Large Exposure to Total Loan (A/B)
- A- Large exposure
- B- Total loans (gross)

19- Loan to Related Party to Net Worth (A/B)
- A- Loan to related parties
- B- Net worth

20- Large Exposure to Net Worth (A/B)
- A- Large exposure
- B- Net worth

21- General Provision to Total Loan (A/B)
- A- General provision
- B- Total loans (gross)

22- Specific Provision to Total Loan (A/B)
- A- Specific provision
- B- Total loans (gross)

23- Specific Provision to NPL (A/B)
- A- Specific provision
- B- NPL

24- All Allowances to Total Assets (A/B)
- A- Total all allowances
- B- Total assets

25- Loans to Deposits (A/B)
- A- Total loans to non-bank customers (gross)
- B- Customer's deposits

## *EARNINGS*

26- ROA (A/B)
- A- Net profit
- B- Total assets

27- ROE (A/B)
- A- Net profit
- B- Equity

28- Gross Yield (A/B)
- A- Interest income
- B- Total assets

29- Net Interest margin (NIM) to Total Asset ((A-B)/C)
- A- Interest income
- B- Interest expense
- C- Total assets

30- Other Income (OTINC) = (A/B)
- A- Other incomes
- B- Total assets

31- Provision to Total Assets (A/B)
- A- Provision
- B- Total assets

32- Overhead (OHEAD) = (A/B)
- A- Non-interest expenses
- B- Total assets

33- Net Income Before Tax (NIBT) = (A/B)
- A- Net income before tax
- B- Total assets

34- Tax to Total Assets (A/B)
- A- Tax
- B- Total assets

35- Interest Margin to Gross Income ((A-B)/C)
- A- Interest income
- B- Interest expense
- C- Gross income

36- Non-interest Income to Gross income (A/B)
- A- Non-interest income
- B- Gross income

37- Non-interest Expense to Gross income (A/B)
- A- Non-interest expense
- B- Gross income

38- Times interest earned ((A+B)/C)
- A- Income before tax
- B- Interest expense
- C- Interest expense

## *LIQUIDITY*

39- Liquid Asset (A/B)
- A- Liquid asset
- B- Total assets

40- Short-term Liabilities (A/B)
- A- Short-term liabilities (less than one year)
- B- Total assets

41- Net Liquid Assets (A-B)/C
- A- Liquid assets
- B- Short-term liabilities
- C- Total liabilities

42- Quick ratio (A/B)
- A- Quick assets
- B- Current liabilities

43- Deposits to Total Loans (A/B)
- A- Total customers' deposits
- B- Total loans to non-bank customers (gross)

Appendix 1 attached to
Prakas No.B7-04-204 Prokor
date December 29, 2004

# The Financial Statement

The financial statements must be prepared in accordance with Cambodian Accounting Standards (CAS) and National Bank of Cambodia (NBC) guidelines. In cases, where current CAS do not stipulate the accounting treatment and/or disclosure requirements, recourse should be made to the International Financial Reporting Standards (IFRS). However, in all situations where a conflict exists between NBC guidelines and CAS or IFRS, NBC guidelines shall take precedence

## 1. BALANCE SHEET

1.1 Banks should disclose the following minimum information in the balance sheet or in the notes to financial statements:

**Assets**

Cash
Balances with central bank
Balances with banks and other financial institutions
Placements with, and loans to, banks and other financial institutions.
Royal Government treasury bills and securities
Other Government treasury bills and securities
Trading securities
Bills receivable
Loans and Advances to customers (note 1.5)
Provisions for Bad and Doubtful Debts
- Specific
- General

Investment securities held (to analyse into equity or debt)
Other assets (to provide a breakdown of major items)
Due from holding company
Due from subsidiary companies (to analyse into equity or debt)

Investments in associated companies (to analyse into equity or debt securities)
Fixed assets (note 1.4)
Properties foreclosed (note 1.4)

**Liabilities**

Deposits and balances of banks
Deposits of non-bank customers
Provision for taxation
Bills and drafts payable
Other borrowings
Other liabilities (to provide a breakdown of major items)
Dividend payable
Due to holding company
Due to subsidiary companies
Debt Securities Issued (note1.3)
Subordinated Debts

**Capital & Reserves**

Contributed Capital (Foreign Branch)

Share capital (authorized and issued and fully paid)

Subordinated Loans

Reserves (to analyse into the various types of reserves) including revaluation reserve (note 1.2)

Retained profits/ Accumulated Loss

1.2 Banks should disclose the amount of each type of reserves at the beginning and end of the financial year, and the amount of any transfers to or form each type of reserves during the year.

| | Common Stock 4012 | General Banking Reserves 4051 | Reserves 4052 | Revaluation of LTMES 4060 | Retained earnings 4070 |
|---|---|---|---|---|---|
| Opening balance<br>+charge to reserves<br>– write back from reserves<br>Ending Balance | | | | | |

1.3 For debt securities issued by the bank with an original maturity of more than one year, banks should disclose the interest rate (for fixed rate securities) or interest fixing method (for floating-rate securities) and repayment date.

1.4 Banks should disclose the market value of quoted investments, bank properties and foreclosed properties. (In accordance with the requirements of the Prakas No B7-01-186 Pror Kor on Fixed Assets of Banks).

1.5 **Loans and advances to customers**

| | Opening balance | Ending balance |
|---|---|---|
| Loans to Government<br>Royal Government of Cambodia<br>Other<br>Commercial Loans<br>Overdrafts<br>Short term loans<br>Long term loans<br>Lease Financing<br>Loans to related parties*<br>Other commercial loans | | |
| Consumer Loans<br>Real estate<br>Overdrafts<br>Other consumer loans<br>Total Loans | | |

* For term "Loans to Related Parties" please refer to the article 49 and 50 in chapter XVI of Law on Banking and Financial Institutions

1.6 Banks should disclose the gross aggregate amount of performing and non-performing loans (secured and unsecured loans), which is defined as loans classified as standard, sub-standard, doubtful and loss in accordance with Prakas

No B7-00-51 on the classification and provisioning for bad and doubtful debts and Prakas No B7-02-145 : Prakas on amendment on Prakas N0 B7-00-51.

| | Ending balance | Opening balance |
|---|---|---|
| Standard loans | | |
| - secured | | |
| - unsecured | | |
| Substandard loans | | |
| - secured | | |
| - unsecured | | |
| Doubtful loans | | |
